# សៀវភៅគតិលោក
## ភាគ ទី៣



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

ChanBoKeo.com

# រឿងសត្វកន្លង់និងគីង្គក់អួតឫទ្ធិគ្នា

មួយទៀតអ្នកមានបញ្ញាទំទេ តតបសេចក្តីយកឈ្នះវិញក៏មាន ដូចនិទាន សត្វកន្លង់តតបនឹងពាក្យគីង្គក់នោះឯង។

មានសត្វកន្លង់១ ហើរក្រេបកេសរផ្កានាកណ្តាលផ្លូវ បានយល់គីង្គក់១លោតទៅខាងគុម្ពផ្កា ទើបសួរថា "បងគីង្គក់ បងឯងទៅឯណា?"។ គីង្គក់ជាសត្វអួតឫទ្ធិ គិតថា អញនឹងប្រាប់គតិនេះឲ្យកន្លង់កោតខ្លាចអញ គិតហើយទើបប្រាប់ថា "យើងទៅកាន់មហាស្រះឯទីព្រៃហេមពាន្ត ដើម្បីនឹងទៅចង់ស្រី, អើកន្លង់ឯងកោតយើងឬទេហះ?"។

ឯកន្លង់តបថា "បងឯងអាចទៅដល់ឬ? ទីព្រៃហេមពាន្តនោះឆ្ងាយម្ល៉េះ"។ "ឱ! យើងទៅវិលល្ងាចផងណ៎ាកន្លង់ ឯងសង្ស័យអ្វីឫទ្ធិយើងនេះ, អើខ្លួនចៅឯង តើធ្វើអ្វីនៅនេះ សូរឮដឹងៗនោះ?។

កន្លង់បានឱកាសក៏តបថា "យើងហើរប្រទក្សិណភ្នំព្រះសុមេរុណ៎ាបងគីង្គក់"។ "ឱ! ឯងហើរប្រទក្សិណជុំភ្នំព្រះសុមេរុនោះធំម្ល៉េះបានឬ?។ "អើ យើងហើរប្រទក្សិណក្នុង១ថ្ងៃបាន៧ជុំផងណ៎ាបងគីង្គក់, បងឯងខ្លាចឫទ្ធិយើងឬទេ?។



ឯគីង្គក់នោះក៏តបកាត់ឡើងថា "ខ្មោចអាឯងស្លាប១សុញទេ នៅអួតភរថាហើរប្រទក្សិណភ្នំព្រះសុមេរុ១ថ្ងៃ៧ជុំបាន អាណាទៅជឿឯងបាន"។

ឯកន្លង់ក៏តបថា "ខ្មោចអាឯងជើងខ្លី១សុញទេក៏អួតភរថាឯងទៅដល់ទីព្រៃហេមពាន្ត វិលល្ងាចវិញបាន អាណាទៅជឿឯងបាន"។ គីង្គក់ក៏ទាល់ឈប់នៅ អស់សេចក្តីតែប៉ុណ្ណេះ។

# រឿងធនញ្ជ័យបណ្ឌិតនិងអ្នកប្រាជ្ញកោះលង្កា

មានអ្នកប្រាជ្ញមួយទៀតបញ្ញាយ៉ាងល្អិត និមិត្តតែឃើញអាការខាងក្រៅចេញមក ក៏អាចដឹងអាថ៌បញ្ហាមនុស្សនោះបាន ដូចនិទានចៅធនញ្ជ័យបណ្ឌិត កាលអ្នកប្រាជ្ញកោះលង្កាទ្វីប គេចូលមកក្នុងព្រះនគរចោទរកអ្នកប្រាជ្ញនោះ សេចក្តីថា កាលណោះព្រះចៅក្រុងកោះលង្កា មានព្រះរាជសារដល់មកព្រះចៅក្រុងស្រីអយុធ្យាថា ឲ្យរើសរកអ្នកប្រាជ្ញ អាចមានបញ្ញាដឹងលោកិយលោកាទ៍ប្រែបាលីភាសាឬឆ្លើយអាថ៌ បញ្ហាក្នុងក្រៅបាន នឹងតតាំងនឹងអ្នកប្រាជ្ញកោះលង្កា។ ឯព្រះចៅក្រុងស្រីអយុធ្យា ក៏ដាក់ភ្នាក់ងារនោះ ឲ្យធនញ្ជ័យទទួលចោទឆ្លើយ តនឹងអ្នកប្រាជ្ញក្រុងលង្កាទើបចៅធនញ្ជ័យទទួលភ្នាក់ងារចេញមក

ចាត់ចែង ឲ្យចៅភ្នាក់ងារកាត់ក្ដារតូចធំ យកសំពត់រុំបន្លំជាគម្ពីរបានច្រើន ហើយឲ្យដាក់ក្នុងទូ ចារឹកចំណងជើងប្រាប់ឈ្មោះទម្ពីរនោះប្លែកៗទីទៃៗ ។

ឯអ្នកប្រាជ្ញកោះលង្កា មកដល់បានចូលទៅមើល ក្នុងមន្ទីរហោត្រៃហ្លួង បានឃើញគម្ពីរចៅធនញ្ជ័យច្រើនដូច្នោះ ក៏នឹកខ្លាចនឹករអាចិត្តគិតថា ស្រុកគេនេះមានគម្ពីរច្រើនណាស់ ឯងនឹងលេងខាងជើងគម្ពីរនោះយល់ជាមិនឈ្នះអ្នកប្រាជ្ញស្រុកអាយនេះទេ បើដូច្នេះត្រូវលេងខាងបញ្ហាក្រៅៗវិញចុះ គិតហើយក៏ចេញមកពហោត្រៃនោះ ហើយឲ្យទូលព្រះចៅក្រុងស្រីអយុធ្យាថា ឲ្យស្ដេចចាត់អ្នកប្រាជ្ញមកចោទឆ្លើយគ្នាជាបញ្ហាទោហារក្រៅនៅរោងក្រៅ ក្នុងវេលានេះ ។ ឯព្រះចៅស្រីអយុធ្យា ក៏ឲ្យចៅធនញ្ជ័យក៏ចេញទៅតទល់នឹងគេរោងក្រៅ ។ ចៅធនញ្ជ័យក៏ទទួលអាជ្ញាចេញទៅទីរោងប្រជុំជន នឹងចោទឆ្លើយបញ្ហានោះ ។ ឯព្រះចៅស្រីអយុធ្យា កាលធនញ្ជ័យចេញទៅតទល់នារោងក្រៅនោះ ស្ដេចចង់ជ្រាបអាថ៌សេចក្ដីបញ្ហាជាឆាប់ទើបត្រាស់ប្រើអមាត្យម្នាក់ឲ្យទៅស្ដាប់បញ្ហា ។ ឯអមាត្យនោះទៅរង់ចាំស្ដាប់មើលជាអ្នកប្រាជ្ញខាងណាថាដូចម្ដេចខ្លះ



ចោទឆ្លើយគ្នា តើយ៉ាងណាខ្លះ ។ ឯអ្នកប្រាជ្ញទាំងពីរខាង ដល់ពេលក៏ឡើងប្រជុំចោទឆ្លើយគ្នាតាមសញ្ញា អ្នកប្រាជ្ញលង្កា ជាអ្នកចោទ កាលចោទនោះប្រើបញ្ហាគ គឺលើកដៃទាំងពីរវង់ឱបជុំវិញ ហើយបង្ហាញទៅចៅធនញ្ជ័យឲ្យទាយ ។

ឯចៅធនញ្ជ័យ ឃើញហើយ ក៏លើកកំភួនដៃ១ បង្ហាញទៅវិញ, ឯអ្នកប្រាជ្ញលង្កាក៏ចូលចិត្តថាធនញ្ជ័យទាយត្រូវហើយ ទើបលើកម្រាមដៃ១ ឡើងបង្ហាញទៅទៀត, ចៅធនញ្ជ័យក៏លើកម្រាមដៃទាំងអស់ឡើង ហើយលោះថយម្រាមកូនដៃ១ចេញ, អ្នកប្រាជ្ញលង្កា ក៏ចូលចិត្តបានក្នុងបញ្ហានោះ, ទើបឲ្យវាយគង ឃោះគោះភេរីហ៊ៅ ឲ្យសព្ទសាធុការដល់ធនញ្ជ័យ មានសេចក្ដីកោតខ្លាចបញ្ញាធនញ្ជ័យ មិនអាចដើម្បីនឹងចោទអាថ៌បញ្ហាតទៅទៀតឡើយ ។

ឯអមាត្យម្នាក់ ដែលស្ដេចប្រើឲ្យទៅចាំស្ដាប់មើលអាថ៌បញ្ហានោះ លុះឃើញអ្នកប្រាជ្ញទាំងពីរចោទឆ្លើយគ្នា តែនឹងដៃតទៅវិញទៅមកដូច្នោះ មិនចូលចិត្តសេចក្ដីថាជាអ្វី ចង់ដឹងសេចក្ដីណាស់នឹងអាលរត់ទៅក្រាបទូលព្រះចៅផែនដីឲ្យជ្រាបមុន យកក្ដីគាប់មុនគេ លុះឃើញចៅធនញ្ជ័យដើរចេញមក ក៏

សាកសួរថា "នែធនញ្ជ័យ, រឿងបញ្ហាដែលអ្នកប្រាជ្ញលង្កាលើកដៃឱបទង់ជុំវិញនោះ តើអធិប្បាយសេចក្ដីដូចម្ដេច? ឯខាងអ្នកឯកលើកកំភួនដៃតទៅនោះ តើមានសេចក្ដីដូចម្ដេច? មួយទៀតខាងគេលើកម្រាមដៃ១បង្ហាញមក, ខាងអ្នកឯងលើកម្រាមដៃទាំង៥ តទៅគេវិញនោះ តើអធិប្បាយសេចក្ដីដូចម្ដេច?។

ឯធនញ្ជ័យ បានឮអមាត្យនោះសួរអាថ៌ដូច្នោះក៏យល់សេចក្ដីថា ចៅនេះបើបានដឹងអាថ៌បញ្ហានេះហើយគង់នឹងទៅក្រាបទូលយកគាប់ មុនអញមិនខានបើដូច្នេះ អញនឹងប្រាប់ឲ្យខុសអំពីអាថ៌បញ្ហានេះចេញឲ្យបានក្ដីខ្មាសនាកណ្ដាលជំនុំព្រះចៅជាម្ចាស់ គិតហើយធនញ្ជ័យក៏ប្រាប់ទៅថា "ឯអ្នកប្រាជ្ញលង្កាដែលឱបដៃជុំវិញនោះ គឺគេសួរយើងថាអង្រុត១ តើរុតបានត្រីប៉ុន្មាន? យើងលើកកំភួនដៃប្រាប់ទៅនោះ គឺថាបានត្រីរ៉ស់១ រួចគេលើកចង្អុលដៃឡើងទៀត គឺគេសួរថា ត្រីរ៉ស់១ បើធ្វើជាងៀត តើបានប៉ុន្មានចំរៀក?, យើងលើកម្រាមដៃទាំង៥ បង្ហាញទៅវិញនោះ គឺថាបាន៥ ចំរៀក"សេចក្ដីយ៉ាននេះឯងចូរចូលចិត្តចុះ"។

ឯអមាត្យនោះជាមនុស្សឥតសតិបញ្ញា នឹងត្រិះរិះឲ្យល្អិតល្អ



គ្រាន់តែឮចៅធនញ្ជ័យប្រាប់ដូច្នោះហើយក៏រត់ម្នីម្នាចូលទៅកាន់ព្រះរាជវាំងជ័យ ។ ឯព្រះចៅផែនដីយល់ហើយក៏ត្រាស់សួរថា "ម្ដេចទៅវ៉ឺយ អ្នកប្រាជ្ញយើង តើស៊ូនឹងគេបានឬទេ? មួយសោតបញ្ហាដែលគេចោទឆ្លើយគ្នានោះ តើមានសេចក្ដីយ៉ាងណាខ្លះ?។ ឯអមាត្យនោះក៏ក្រាបទូលអាថ៌បញ្ហាតាមពាក្យធនញ្ជ័យប្រាប់នោះ សព្វប្រការ ។ ឯបរមក្សត្រាធិបតី បានស្ដាប់ពាក្យអមាត្យនោះទូលដូច្នោះហើយ ក៏ត្រាស់ថា "បញ្ហាអ្វីនិយាយពីអង្រុតរុតត្រីធ្វើងៀតដោងដូចជាប្រដៅកូនក្មេង វាចោទគ្នាលេងដូច្នោះ ក៏ឯអ្នកប្រាជ្ញកោះលង្កានោះល្បីថាខ្លួនចេះដឹងក្នុងគម្ពីរសាស្ត្របាលី នឹងហេតុលោកិយលោកា គួរតែសម្ដែងពីគតិលោកឬគតិធម៌ ជាអាថ៌សុខុមគម្ពីរភាពនោះ ទើបគួរសមជាអ្នកប្រាជ្ញរាជបណ្ឌិតបាន នេះហេតុអ្វី ទៅយករឿងអង្រុតថ្នងមកចងជាបញ្ហាចោទឆ្លើយគ្នាយ៉ាងនេះ, នែអមាត្យ បញ្ហានោះក្រែងមិនដូចឯងយកមកសម្ដែងនេះទេដឹង?។

អមាត្យទូលថា "ពិតមែន ព្រោះបានសាកសួរផ្ទាល់នឹងធនញ្ជ័យនោះប្រាកដហើយ"។ ឯចៅធនញ្ជ័យកាលសម្រេចកិច្ចចោទឆ្លើយនោះហើយ ក៏រៀបអាត្មា ចូលទៅគាល់មហាក្សត្រនាចុង

ព្រះរាជវាំង ។

ឯមហាក្សត្រធិបតី យល់ថាធនញ្ជ័យមកគាល់ព្រះអង្គដូច្នោះក៏ត្រាស់សួរថា "អើ ធនញ្ជ័យ រឿងបញ្ហាដែលអ្នកប្រាជ្ញលង្កាគេឱបវង់ដៃ ហើយចៅឯងលើកកំភួនដៃតតបទៅវិញនោះមានអាថ៌សេចក្ដីដូចម្ដេច? មួយទៀត ខាងគេលើកម្រាមដៃ១ឡើងហើយ ចៅឯងលើកម្រាមដៃទាំង៥ តតបទៅវិញនោះតើមានសេចក្ដីដូចម្ដេច? ចូរចៅអធិប្បាយទៅមើល! ។ ឯធនញ្ជ័យក៏អធិប្បាយថ្វាយសេចក្ដីថា "អ្នកប្រាជ្ញលង្កាលើកដៃវង់ជុំវិញនោះ គឺចោទថា ក្នុងចក្រវាលយើង១ នេះមានមានភ្នំជាទីតាំងសម្រាប់លោកតើប៉ុន្មាន?, ទូលព្រះបង្គំជាខ្ញុំលើកកំភួនដៃនោះ គឺប្រាប់គេថាមានភ្នំព្រះសុមេរុ១ ជាធំជាទីតាំងសម្រាប់លោកយើងនេះដល់ក្រោយគេលើកម្រាមដៃ១ ឡើងនោះគឺគេចោទថា ក្នុងភទ្ទកប្បយើង១នេះ មានព្រះពុទ្ធត្រាស់ប៉ុន្មានព្រះអង្គ? ទូលព្រះបង្គំជាខ្ញុំលើកម្រាមទាំង៥ឡើងឆ្លើយទៅថា មានព្រះពុទ្ធត្រាស់៥ព្រះអង្គ, ទូលព្រះបង្គំជាខ្ញុំលោះម្រាម១ ចុះប្រាប់ថាព្រះពុទ្ធត្រាស់បាន៤ព្រះអង្គទៅហើយ នៅសល់១ព្រះអង្គគឺព្រះអរិយមេត្រី ព្រះអង្គពុំទាន់ចុះមកត្រាស់, សេចក្ដីចោទ



ឆ្លើយគ្នានោះមានសភាពយ៉ាងដូច្នេះសូមទ្រង់ជ្រាប" ។

ឯព្រះចៅ ស្រីអយុធ្យាបានទ្រង់ព្រះសណ្ដាប់ស័ព្ទអាថ៌បញ្ហានោះហើយ ស្ដេចក៏មានព្រះរាជហឫទ័យត្រេកសោមនស្សត្រាស់ថា "អើ សេចក្ដីបញ្ហាយ៉ាងនេះទើបសមគួរ ជាគតិលោកគតិធម៌បាន, ត្រូវលំអានជាតិបណ្ឌិតគប្បីពោលហើយ, ចុះអមាត្យនេះគេចេះពីណាមក បានជាមកប្រាប់យើងថាទៅជាអង្រុតវុតត្រីធ្វើជាជៀត៥ ចំរៀកផ្ដេសផ្ដាសដូចជាប្រដៅកូនក្មេងគង្វាលក្របីវាចោទគ្នាលេងនោះ សមគួរឬជាពាក្យអ្នកប្រាជ្ញបំណាច់មកពីកោះលង្កា ល្បីថាជាអ្នកចេះគតិធម៌គតិលោក ទៅយោគយករឿងអង្រុតថ្ងងមកជាបញ្ហានោះ គេមានព្រើលកាលឯណាវាព្រើលឯអមាត្យឯងនេះ ចេះមកកាច់មួលពាក្យគេដែតផ្ដាសសោះជាម្ដង ",ស្ដេចត្រាស់ហើយក៏ទ្រង់ព្រះរាជទានមាសប្រាក់ ដែកវិកង សំពត់អាវដៃស្បៃ ឲ្យចៅធនញ្ជ័យបណ្ឌិតតាមក្ដីគាប់ ។

ឯអមាត្យនេះ ត្រូវស្ដេចបន្ទោសបានសេចក្ដីខ្មាសគេ នាកណ្ដាលជំនុំធំ គិតខឹងនឹងចៅធនញ្ជ័យ ដេវពោលដែតក្នុងពោះថាខ្មោចអាព្រើលយ៉ាងនេះ វាចង់ថាដូចម្ដេចក៏ថាទៅ ធ្វើឲ្យអញ

បានសេចក្ដីខ្មាសគេ នាកណ្ដាលប្រជុំជនយ៉ាងនេះ ៗ

ចប់រឿងបញ្ហាដៃ

## រឿងអមាត្យព្រះបាទពិម្ពិសាររាជនិង អជាតសត្រូវរាជកុមារ

សេចក្ដីក្នុងរឿងធនញ្ជ័យ មានអាថ៌បញ្ហាពិស្ដារទៀត នៅមានច្រើនណាស់ ក្នុងទីនេះយើងទាញយកតែបញ្ហា១នេះ មកសម្ដែងឲ្យឃើញសេចក្ដីថា អ្នកប្រាជ្ញមានបញ្ញាហើយ អាចដឹងអាចស្គាល់ក្នុងអាការលើកដៃ ឱបដៃ ឬឃើញតែកិរិយាក្រៅរបស់អ្នកដទៃក៏អាចដឹងសេចក្ដីនោះបាន ៗ មួយទៀតអ្នកមានបញ្ញានោះប្រៀបដូចប្រទីបបំភ្លឺ ឆ្លុះមើលនូវទីងងឹតទីកំបាំងបាន ៗ មួយទៀតអ្នកមានចំណេះវិជ្ជាសព្វសរពើហើយតែបើពុំមានបញ្ញានឹងពិចារណាត្រិះរិះ តាមសម័យផងសព្វវិជ្ជានោះក៏ពុំអាចរុងរឿងថ្លាទៅបាន លុះតែមានបញ្ញាសតិសម្បជញ្ញៈផង ទើបធ្វើសព្វវិជ្ជានោះ ឲ្យរុងរឿងឡើងបាន មានទិនាប្រៀបដូចយ៉ាងរាជអមាត្យព្រះបាទពិម្ពិសារទាំង៣ពួកនោះឯង ៗ



ដំណើរថា កាលព្រះអជាតសត្រូវរាជកុមារស្ដាប់ពាក្យទេវទត្តត្ថេរ ញុះញង់ឲ្យសម្លាប់ព្រះបាទពិម្ពិសារជាព្រះរាជកុមារសៀតកាំបិតគ្រឿងប្រហារចូលទៅក្នុងព្រះរាជវាំង ដើម្បីនឹងពិឃាតព្រះវររាជបិតា ៗ ឯពួករាជអមាត្យនាយតម្រួតរក្សាអង្គ បានឃើញព្រះរាជកុមារចូលក្នុងព្រះមន្ទីរខុសកាលដូច្នោះ ក៏ហាមឃាត់មិនឲ្យចូល ឯព្រះរាជកុមារចេះតែចចេសចូលទៅ ទើបនាយតម្រួតនាំគ្នាចាប់ត្រួតមើលក្នុងអង្គកាយ បានឃើញកាំបិតគ្រឿងប្រហារព្រះរាជកុមារសៀតមកដូច្នោះ ក៏ចាប់ចងដាក់ទោសតាមរាជបញ្ញត្តិ ហើយនាំគ្នាពិភាក្សាទោសព្រះរាជកុមារៗក៏ឲ្យការតាមខ្លួនគិតសម្លាប់បិតានោះ ៗ ឯនាយតម្រួតទី១ឆ្លើយឡើងថា "ទោសក្បតិនេះត្រូវសម្លាប់ព្រះរាជកុមារផង ត្រូវសម្លាប់ព្រះទេវទត្តត្ថេរ និងលោកសង្ឃបណ្ដាជាពួកគប់គិតចូលគំនិតគ្នាទាំងអស់ផង" ៗ ឯនាយតម្រួតទី២ឆ្លើយឡើងថា "ទោសក្បត់នេះត្រូវសម្លាប់តែព្រះរាជកុមារនិងព្រះទេវទត្តត្ថេរ ទើបគួរ, ឯបណ្ដាលោកសង្ឃឯទៀតៗនោះមិនត្រូវសម្លាប់ទេ ព្រោះលោកពុំបានដឹងឮផង" ៗ ឯនាយតម្រួតទី៣ជាមន្ត្រីមានសតិសម្បជញ្ញៈឆ្លើយឡើងថា "លោកអ្នករាល់គ្នាកាត់

ទោសយ៉ាងនេះមិនត្រូវទេ, ឯទោសនេះបើរូបអ្នកដទៃឯទៀតនោះគួរហើយ តែនេះព្រះរាជកុមារជាព្រះរាជបុត្រារបស់លោក, ព្រះទេវទត្តសោតជាវង្សសាក្យបុត្តិយ៍ព្រះចៅជាម្ចាស់ក៏រាប់អានគោរពប្រតិបត្តិ យើងនឹងកាត់ទោសពីឃាតឯងថា កាចឯណាបាន ទោសនេះហួសវិស័យយើងជាមន្ត្រីពិភាក្សា គួរតែនាំគ្នាឡើងក្រាបទូលឲ្យទ្រង់ជ្រាប បើជាទ្រង់ប្រោសយ៉ាងណា? ក៏តាមតែព្រះអង្គលោកចុះ ព្រោះកូនគេ អាពុកគេថាយ៉ាងណាសឹមយើងធ្វើតាមជាក្រោយ"។ ឯនាយតម្រួតទាំង៣ពួក ពិគ្រោះគ្នាឃើញផ្លូវវៀងខ្លួនយ៉ាងនេះទើបនាំគ្នាចូលទូលព្រះបាទពិម្ពិសាររាជបិតា តាមដំណើរដែលព្រះអជាតសត្រូវកុមារ ប្រតិបត្តិការខុសប្រពៃណី កន្លងព្រះរាជបញ្ញត្តិនោះសព្វប្រការ ។ ឯព្រះបាទពិម្ពិសារស្ដេចជ្រាបហើយ ទើបត្រាស់ថា "អើទោសយ៉ាងនេះ អ្នកទាំងឡាយពិភាក្សាទៅ តើយល់ដូចម្ដេច?។

ឯអមាត្យទាំង៣ ពួក ក៏ក្រាបទូលតាមដំណើរដែលខ្លួនគិតយល់ផ្សេងៗគ្នានោះឯង ទើបព្រះរាជពិម្ពិសាររាជស្ដេចទ្រង់ត្រាស់ថា "អើពួកនាយតម្រួតទី១ ពិភាក្សាថា ត្រូវឲ្យសម្លាប់ទាំងព្រះទេវទត្តត្ថេរនិងព្រះសង្ឃទាំងពួង ព្រមទាំងព្រះរាជកុមារ



ផងនោះពាក្យវិនិច្ឆ័យនោះយល់កើនហួសណាស់ ត្រូវឲ្យដកងារបន្ថយយសសក្តិ ក៏ឯអមាត្យទី២ ពិភាក្សាថា ត្រូវឲ្យសម្លាប់ព្រះរាជកុមារ ព្រមទាំងព្រះទេវទត្តត្ថេរនោះ ពាក្យវិនិច្ឆ័យនោះត្រូវបន្ថយប្រាក់ខែបៀវត្សរ៍ឯអមាត្យទី៣ ពីភាក្សាថាត្រូវឡើងក្រាបទូលសិននោះ ពាក្យវិនិច្ឆ័យនោះ ត្រូវឲ្យឡើងយសសក្តិប្រាក់ខែបៀវត្សរ៍ថែម ព្រោះជាអ្នកមានសតិសម្បជញ្ញៈចេះពិចារណាត្រូវតាមវត្ថុ តាមសម័យកាល"។

រឿងនិទាននេះ មានសេចក្ដីពិស្ដារនៅក្នុងព្រះគម្ពីរសុត្តន្តបិដកឯណោះ ឯងស្ដាប់មើលចុះ លោកអ្នកមានសតិសម្បជញ្ញៈពិចារណាមើលវត្ថុមើលសម័យកាលគួរដល់កាលនេះសឹងចំរើននូវយសសក្តិបរិបូណ៌បាន អ្នកមានសតិស្មារតីនេះ មិនដែលភ្លាត់ភ្លើទៅក្នុងការភ្នាក់ងារដែលខ្លួនធ្វើ គឺនឹងដើរក្ដី អង្គុយក្ដី ដេកក្ដី ឈរក្ដី ឬលើកដៃ លើកជើង លាតបត់ដៃបត់ជើងក្ដី ឬបរិភោគភោជនាហារជាវត្ថុទន់ឬរឹងក្ដី កាលទំពាស៊ីកាលលេបចូលទៅក្នុងពោះក្ដី តែបើពុំមានសតិស្មារតីនឹកជាមុនហើយ ការអស់នោះសឹងភ្លាត់ទៅផ្សេងៗមានដួលប៉ះត្រូវបន្លាជាដើម បើខាងបរិភោគផឹកស៊ីសោត មានស្លាក់ឆ្អឹងត្រី ត្រូវម្ទេសហើរជាដើម

អ្នកគ្មានសតិបញ្ញានោះ លោកថា ជាមនុស្សប្រកាន់សេចក្ដីប្រមាទមួយនេះ មាននៅលើបុគ្គលណាហើយបុគ្គលនោះនឹងតាំងខ្លួនឲ្យមាំមួនពុំបាន បើធ្វើការអ្វីការនោះខូចបង់វិញ, ដូចនិទានស្មៀនកាន់ភ្នាក់ងាររក្សាឈើរាជការរបស់ព្រះបាទពិម្ពិសាររាជនោះឯង ។

## រឿងព្រះធនិយថេរនិងនាយសមុហបញ្ជី

រឿងនោះមានសេចក្ដីថា កាលណោះមានព្រះមហាថេរ១អង្គឈ្មោះព្រះធនិយថេរ ជាកូនអ្នកស្មូនឆ្នាំង ថ្ងៃ១ព្រះថេរនោះទៅឆយកឈើរាជការអំពីនាយសមុហបញ្ជីថា បណ្ដាយឈើទីព្រៃព្រឹក្សាលតាវល្លិទាំងឡាយនោះ ព្រះបាទពិម្ពិសាររាជស្ដេចទ្រង់ព្រះសទ្ធាបានទេវថ្វាយ ដល់ព្រះភិក្ខុសង្ឃមានព្រះសម្មាសម្ពុទ្ធជាប្រធានហើយ ឥឡូវអាត្មាភាពត្រូវការឈើធ្វើកុដិ ចូរអ្នកឯងចាត់ចែងឈើគ្រឿងទព្វសម្ភារៈអស់នេះ ដល់អាត្មាភាពចុះ ។

ឯនាយសមុហបញ្ជីនោះ ជាមនុស្សពុំមានសតិសម្បជញ្ញៈពិចារណាឲ្យយល់ការថា ឈើនេះគឺគេកាប់ចាំងអារកាត់ ជាគ្រឿងទព្វសម្ភារៈស្រេច ជារបស់រាជការត្រូវការ, មួយទៀត



សូម្បីនឹងមានសំបុត្រ១ច្បាប់ជំរាបសួរទៅដល់មហាមាត្យជាធំឲ្យក្រាបទូលថាឈើនោះ ឥឡូវលោកសង្ឃមកយកទៅធ្វើកុដិជាទ្រង់ប្រគេនឬម្ដេចយ៉ាងនេះពុំមាន និមិត្តតែព្រះធនិយថេរមកឆដូច្នោះ ក៏ឆោតតាម លើកយកឈើអស់នោះឲ្យទៅព្រះធនិយថេរ ដោយអំពើចិត្តឥតពិគ្រោះ ។ ឯព្រះធនិយថេរក៏ដឹកនាំយកឈើនោះទៅ ធ្វើកុដិតាមសេចក្ដីប្រាថ្នារបស់ខ្លួន ។

លុះនៅមក នាយជាងចៅភ្នាក់ងារធ្វើរាជការជួសជុលព្រះរាជតំណាក់ អស់ឈើនឹងធ្វើតទៅទៀតទើបជំរាបដល់មហាមាត្យ ។ ក៏ឲ្យចៅភ្នាក់ងារទៅនាំយកឈើនោះ ។ ឯនាយសមុហបញ្ជីក៏តបមកថា ឈើអស់នោះពុំមានទេ ដ្បិតព្រះធនិយថេរលោកមកយកទៅធ្វើកុដិផុតអស់ហើយ ។

ពាក្យអស់នោះពុំស្ងាត់ ក៏ឮជ្រាបដល់ព្រះបាទពិម្ពិសាររាជៗសេចទ្រង់បន្ទោសនាយសមុហបញ្ជីជានាយស្មៀននោះជាអនេកបរិយាយផ្សេងៗហើយទ្រង់នាំហេតុនោះ ទៀងក្រាបបង្គំទូលព្រះសម្មាសម្ពុទ្ធជាម្ចាស់ តាមរឿងព្រះធនិយថេរទៅឆយកឈើរាជការមកធ្វើកុដិ ។

ទើបសម្ដេចព្រះជិនស្រីទ្រង់យកវត្ថុនិទាននោះជាបឋម

អទិន្នាទានបារាជិ បញ្ញត្តសិក្ខាបទអទិន្នាទានបារាជិកដល់ភិក្ខុទាំងឡាយក្នុងព្រះពុទ្ធសាសនាតមក ។

រឿននេះមានសេចក្ដីពិស្ដារនៅក្នុងគម្ពីរព្រះវិន័យបិដកឯណោះ គួរចូលចិត្តចុះ ។ ក៏ឯរឿងនិទានបុគ្គលមានបញ្ញាចេះពិចារណាមើលជុំវិញនោះ សឹងចំរើនរុងរឿងបាន ដូចនិទាននាយតម្រួតទី៣ ដែលវិនិច្ឆ័យរឿងក្ដីព្រះអជាតសត្រូវជារាជកុមារនោះឯង ។

## បណ្ឌិតវគ្គោ និដ្ឋិតោ

រឿងបណ្ឌិតវគ្គនេះមានវត្ថុនិទាននៅច្រើនណាស់ យើងពុំឈ្នះនិងពណ៌នាឲ្យពិស្ដារទៅបាន សំដែងមកតែប៉ុណ្ណោះ ជាន័យសង្ខេបទុកជាបែប ឲ្យចៅឯងគិតមើលជាគតិលោកយោគទៅតាមហេតុដែលកើតឡើងមានឡើងតទៅខាងមុខទៀតចុះ ។

### ក្នុងបណ្ឌិតវគ្គ សន្មតចប់តែប៉ុណ្ណោះហោ

បងអើយបណ្ឌិត លោកត្រិះរិះគិត អាការរាក់ជ្រៅផ្លូវណា
ចម្រើន ក្រវើនត្រាច់ទៅ ផ្លូវណាមិនត្រូវ មិនត្រាច់ទៅត្រាច់ ។
ហេតុណាកើតផល ផលណាមកពាល់ ប្រាជ្ញប្រៀបផ្ទឹមសាច់ ធ្លុះ
កិច្ចឈ្លេចកល យល់មូលវំពេច សតិមិនភ្លេច មិនភ្លាត់តាមភ្លើន ។



កូនសិស្សសួរគ្រូថា សូមទានរឿងគតិពាលគតិប្រាជ្ញ "ពាលនាំឲ្យកាច ប្រាជ្ញនាំឲ្យស្លូត" នោះខ្ញុំចូលចិត្តហើយ តែគតិមនុស្សឆោតល្ងង់នោះ ក្ដីឃ្លានបាយ ឃ្លានមាន ឃ្លានស្រឡាញ់៣ ប្រការនោះលោកគ្រូអធិប្បាយពុំទាន់ពិស្ដារ ។ ក៏ឯកិរិយាឆោតនោះអ្នកខ្លះពុំមានក្ដីឃ្លាន៣ ប្រការនោះទេ តែនៅឆោតក៏មានសូមទានអធិប្បាយតទៅទៀត" ។

គ្រូតបថា "សេចក្ដីឆោតប៉ុន្មានៗនោះនៅរួមក្នុងគតិគ្មានសតិសម្បជញ្ញៈនេះឯង អ្នកគ្មានសតិបញ្ញានឹងពិចារណាមើលហេតុ មើលបច្ច័យ មើលចុងមើលដើមផ្ទឹមហេតុប្រៀបផលឲ្យដល់គ្នាហើយ អ្នកនោះនៅក្នុងឆោតមិនលែង" ។ យើងសួរឯងវិញ បញ្ហាថាអ្វីដែលជ្រៅក៏ក្រលែងជ្រៅ, អ្វីរាក់ក៏ក្រលែងរាក់នោះ ចូរឯងសំដែងទៅមើល? ។

កូនសិស្សតបថា "ជ្រៅក៏ក្រលែងជ្រៅនោះ បានដល់ខាងព្រះញាណព្រះពុទ្ធ ឬព្រះសទ្ធម្មគម្ពីរភាព, ឯរាក់ហើយក៏ក្រលែងរាក់នោះបានខាងបញ្ញាកូនក្មេង" ។

គ្រូឆ្លើយថា "អើ បញ្ញាកូនក្មេងតូចដូចទឹករាក់ពិត, ក៏ឯជាតិទាំងឡាយ បញ្ញានៅរាក់សតិសម្បជញ្ញៈនៅពុំទាន់កើតឡើង

ក្លាហាន ទើបបាននៅឆោត ឯងស្តាប់មើលចុះ ជាតិទារកដែលយំកាលណា ចាស់ៗ លោមបញ្ឆោតថា អាវ៉ាកុំយំចាំម៉ែទៅវ៉ាយអានោះឲ្យមេនោះឲ្យ ជួនណាថាស្ដោះទឹកមាត់លើបាតដៃ សិមម៉ែវ៉ាយឲ្យ ជួនណាបញ្ឆោតថា កុំយំខ្លាចទីងមោងវ៉ាមកខាំ, ជួនណាថាកុំដេកនៅលើគេ ក្រែងតាព្រេងចាក់ទឹកបាយ លើក្បាល ជួនណាថា កុំលេងអង្គុរវ៉ាមុខរឹង, ចាស់ៗបញ្ឆោតយ៉ាងនេះជាដើម ៗ ឯទារកគ្មានសតិសម្បជញ្ញៈយ៉ាងនេះ ទើបឆោតឲ្យចាស់ៗបញ្ឆោតបាន ៗ ជាតិមនុស្សទាំងឡាយដែលឆោតនោះ ព្រោះពុំមានសតិសម្បជញ្ញៈដូចទារកនោះឯង ៗ ក៏ឯក្ដីឃ្លាន ក្ដីប្រាថ្នារបស់មនុស្សនោះ ជាផ្លូវឲ្យអាពាលវ៉ាបញ្ឆោតបាន ដូចបានសំដែងមកហើយ ក្នុងពាលវគ្គខាងក្រោយ ៗ

មួយទៀតមនុស្សឆោតនោះ ព្រោះពុំស្គាល់លោកធម៌ទាំង៨ ប្រការគឺៈ លាភ១ អលាភ១ យស១ អយស១ សុខ១ ទុក្ខ១ សរសើរ១ និន្ទា១ ធម៌៨ ប្រការនេះជាធម៌របស់លោក សត្វលោកសឹងវិលទៅតាមធម៌ទាំង៨ ប្រការជាប្រក្រតី ក្ដីលោភ ក្ដីយសសក្ការៈ ក្ដីសុខសម្រាន្ត ក្ដីសរសើរតំកើងតំកល់ធម៌៤ប្រការនេះ សត្វលោកប្រារព្វចង់បាន ៗ



ឯក្ដីអលាភគឺខាតលាភ ក្ដីអយសគឺថយយសសក្ដា ក្ដីទុក្ខរំខាន ក្ដីនិន្ទាគរហាតិះដៀល ធម៌៤ប្រការនេះ សត្វលោកសឹងស្អប់សឹងខ្ពើមពុំចង់បានឡើយ, តែនឹងគេចកែវត់ឲ្យផុតចេញទៅពុំបាន ទោះជាមិនចង់បានក៏ចង់បានដដែល ព្រោះសភាវធម៌ជាគូៗនឹងគ្នា បុគ្គលណាប្រាថ្នាតែលាភ យល សុខ សរសើរ ចំណែក១ ធ្វើម្ដេចនឹងបានធម៌៤ យ៉ាងនេះស្ថិតស្ថេរនៅជាប្រក្រតីបាន សភាវធម៌៨ ប្រការនេះជារបស់សម្រាប់លោក លោកតែងវិលទៅតាមធម៌៨ ប្រការនេះឯង ៗ

បុគ្គលណាប្រាថ្នាតែលាភ យស សុខ សរសើរ៤ ប្រការនេះហើយ គង់នៅក្នុងឆោតមិនលែងឡើយ, ឯងស្ដាប់មើលចុះ រឿងគ្រូកណ្ដាញ់នៅស្រុកមាត់ជ្រូក១ គ្រូហមដើងបាក់ នៅស្រុកមង្គលបូរី ល្បីដល់ស្រុកបាត់ដំបង១ គ្រូបង់បទ១ គ្រូអស់នេះអាអ្នកលេង វ៉ាក្លែងតែងកលឧបាយផ្សាយពាក្យអួតថា ពូកែឆុតឆាប់ អាចរម្ងាប់សព្វរោគអ្នកនគរបាន ៗ

ឯអ្នកនគរណាលុះអំណាចធម៌៤ យ៉ាងខាងលើហើយ សឹងដំផ្អើលគឹកកងនាំគ្នាយកទៀនធូបប្រាក់កាសជួលកប៉ាល់ជិះទៅរកគ្រូពូកែនោះ ៗ ពួកចិននាយកប៉ាល់បានប្រាក់ថ្លៃកប៉ាល់ក៏..

បរិបូណ៌ កាលអ្នកនគរត្រូវការទៅស្រុកមាត់ជ្រូក ក្នុងកាលនោះ
ឯង ។

មួយទៀតមានទឹកបឹងទី១ នៅខែត្រស្រុកទឹកជោរកាលនោះ
មានក្របីឈើភ្នែក១ វាចុះទៅត្រាំទឹកបឹងនោះរឿយៗលុះយូរ
ថ្ងៃមក ភ្នែកក្របីនោះជាឡើងដូចប្រក្រតីៗឯអ្នកស្រុកនោះ
ឃើញក្របីនោះជាភ្នែកហើយក៏កើតសេចក្ដីជឿថា ទឹកបឹង
នោះពូកែ នាំគ្នាទៅងូតទៅដងយកមកផឹក កើតមានគ្រឿង
សក្ការបូជាអុជទៀនធូបបូជាទឹកបឹងនោះ កិត្តិសព្ទ៍ឮខ្ចរខ្ចាយ
សុសសាយដល់អ្នកស្រុកសៀមរាប់ ស្រុកបាត់ដំបង កើតជឿនាំ
គ្នាទៅបូជាសូមទឹក យកទឹកនោះ ជាកោលាហល ដល់ជ្រាបទៅ
លោករាជការៗ ឲ្យទៅហាម ឃាត់បណ្ដាពួករាស្ត្រឆោតទាំង
នោះ ។

មានរឿងមួយទៀត គឺមានដើមដង្កោ១ដើមរលើងឫសរលំ
ចុងចុះដល់ដី នៅមកជាយូរខែ អ្នកស្រុកដើរទៅមក ក៏បានដល់
តែរាល់គ្នា ថ្ងៃមួយមានចៅម្នាក់ទៅកាប់ចុងមែកដង្កោនោះចេ
ញខ្លះ ឯដើមដង្កោនោះ កាលគេកាប់ចុងស្រាលចេញហើយ ក៏
ងើបឡើងដោយកម្លាំងឫសទាញបន្តិច ។



ឯអ្នកស្រុកបានឃើញដើមដង្កោនោះហើយ ក៏ចូលចិត្តជឿ
ថាពូកែ ទើបនាំគ្នាយកទៀនធូបទៅអុជបូជាសូមស្ដោះសម្បក
យកជាថ្នាំកែរោគផ្សេងៗ អ្នកខ្លះកាត់យកឫសយកមែកធ្វើជា
ថ្នាំ ជាកូនសង្កត់ចងដៃចងចង្កេះផ្ដាសទៅ, ឯដើមដង្កោនោះត្រូវ
អ្នកស្រុកស្ដោះសម្បកអស់រសជាតិផែនដីផ្សាយមិនដល់ចុង ក៏
វិនាសរូបកាយតាយហោងបង់ ។

មានរឿងមួយទៀត គឺអ្នកស្រុកនៅទិសខាងលិចថ្ងៃ១ មាន
គោខ្មៅក្មេងស្ទាវ១ ជារបស់អ្នកឯណាពុំដឹង គោនោះដើររកស៊ី
ទៅតាមហ្វូងវា ។ ឯអ្នកស្រុកឃើញគោខ្មៅនោះរូបល្អ ក៏សំគា
ល់ថា ព្រះគោរត់មកអំពីស្រុកសៀម ទើបនាំគ្នាដេញចាប់ក៏
ពុំបានអ្នកខ្លះរត់តាមពីក្រោយ ស្រែកដង្ហោថា ព្រះអង្គម្ចាស់អើយ
ឈប់ប្រោសសត្វដែលខាត់ក្រ អ្នកខ្លះបានចេកទុំ បានស្មៅ ស្រូវ
រត់តាមទៅឲ្យគោៗនោះមិនឈប់នៅ ចេះតែទៅតាមកម្លាំង
វា ។

ឯបណ្ដាអ្នកស្រុកទាំងប្រុសស្រី នាំគ្នារៀបគ្រឿងបូជា
ផ្សេងៗហើយត្រាច់ទៅតាមគោនោះឯង, ឯគោនោះលុះឃើ
ញមនុស្សគេមកចោមដុំខ្លួន នឹងរកចន្លោះប្រេកបោលចេញពុំ

រួចដូច្នោះ ក៏ដាលបោលសម្រុកពារត្រង់មកជំនុំមនុស្សច្រើន មនុស្សទាំងឡាយក៏ផ្អើលរត់ប្រៀតដែកគ្នាទៅទីទៃៗ អ្នកខ្លះដួលបែកដៃបែកជើង អ្នកខ្លះដួលផ្កាប់មុខកំពប់ទៀនធូបជិះជាន់នៅលើគ្នា ដោយក្ដីភ័យនឹងស្នែងគោនិងក្របកជើងគោៗនោះ បោលបោះផ្លោះកន្លងមនុស្សរួចចេញបាន ក៏បោលទៅរកហ្វូងវាដែលធ្លាប់នៅជាមួយគ្នាអំពីដើម ។ ឯមនុស្សទាំងឡាយបានក្ដីទុក្ខវេទនាពិការដៃជើងជាដើម ក៏នាំគ្នាវិញទៅស្រុកវិញ ។

រឿងនេះចូលឯងស្ដាប់មើលចុះ មនុស្សគ្មានសម្បជញ្ញៈ ត្រិះរិះឲ្យឃើញហេតុឃើញវត្ថុជាទីឯណាអាងបាន គួរឬ ទៅជឿទៅបូជាសត្វតិរច្ឆានឲ្យបាននូវក្ដីទុក្ខវេទនាដូចពណ៌នាមកនេះទាំងនេះក៏ព្រោះគ្មានសតិសម្បជញ្ញៈ ពិចារណាឲ្យយល់ដើមហេតុ គឺគោនោះ តើជាគោមានជីវិតពិតដូចគោធម្មតា ឬ យ៉ាងណា កាលគោនោះនៅស្រុកខ្មែរយើងណាខ្លះ, កាលស្ដេចនរេសូរសៀមលើកទ័ពមកវាយស្រុកខ្មែរយើងគឺបន្ទាយលង្វែកបែកបាននាំយកគោនោះ តើពីឆ្នាំណា? ពីចុល្លសករាជប៉ុន្មាន?។ បើគិតទៅតាំងអំពីឆ្នាំ រាជ្យនរេសូរវាយបន្ទាយលង្វែក ដល់មក



សម័យនេះ កន្លងទៅជាង២០០ ឆ្នាំទៅហើយ គោនោះនឹងរស់នៅដល់ឥឡូវនេះម្ដេចបាន គោឯណាអាយុវែងម្ល៉េះ!។

មួយបើគោនោះ ជាងគេធ្វើដោយថ្មឬដោយសំរឹទ្ធិវិចិត្រដោយមាសដោយប្រាក់ទេ អើហេតុអ្វីគោរូបនោះ ម្ដេចចេះបោល ចេះបរចរចេញរត់មកស្រុកខ្មែរវិញបាន។

មួយមានពាក្យព្រេងថា គោនោះគឺសៀមគេយកទៅបោះភ្ជាប់ជើងទាំង៤ ដោយដែកគោល យកច្រវាក់ចង់ក្រៀកដោយជុំវិញ ពុំឲ្យរត់ចេញទៅណាបាន ហើយហាមមិនឲ្យពួកខ្មែរយើងនេះ ចូលទៅមើលជិត ថាបើខ្មែរទៅជិតហើយ ក្រែងខ្មែរនិយាយជាភាសាខ្មែរ គោនោះកាលបើឮភាសាខ្មែរហើយក៏កញ្ជ្រោលបម្រាស្រែកយំកងរំពងខ្លាំង។

ពាក្យព្រេងនេះ ឯងស្ដាប់មើលចុះ គួរឬគោសំរឹទ្ធិទេ ម្ដេចចេះយំស្រែក ខាងសៀមសោត ម្ដេចបាំទៅបោះដែកគោលចងក្រៀកនោះ ឆ្កួតឬ រូបគោសំរឹទ្ធិ (ពាក្យព្រេងនេះមិនគួរនឹងជឿស្ដាប់សោះ)។

ឯជាតិអ្នកកាន់គោជាព្រះនោះក៏មានខ្លះ ដូចយ៉ាងសាសន៍ព្រាហ្មណ៍ជំពូក១ គឺជាតិឥណ្ឌូធានីគេកាន់សាសនាឥសូរនារាយណ៍

ខ្លះកាន់សំពះយោនីនាងឧមាភគវតី, ខ្លះកាន់សំពះអង្គជាតិព្រះសយម្ភូ គឺលិង្គព្រះឥសូរ, ខ្លះកាន់សំពះគោដែលជាយានរបស់ព្រះឥសូរ, ពួកអស់នេះ សឹងមានសទ្ធាសាងព្រះវិហារតំកល់គោខ្មៅតាំងជាព្រះអង្គថាព្រះគោ នាំគ្នាយកអាចម៍គោនោះដុតជាផង ហើយលាបថ្ងាស លាបមុខទុកជាស្រីសួស្តីមង្គល ៗ ចុះពួកខ្មែរយើងនេះកាន់សំពះសាសនាព្រះសម្មាសម្ពុទ្ធ គឺគោតមបរមគ្រូទេ ហេតុម្តេចក៏ទៅសំពះបូជាគោ តាំងនាមជាព្រះគោ ហើយមានសេចក្តីសៅសោកអាល័យដល់ព្រះគោ ដែលនគរសៀមគេយកទៅនោះ ខ្មែរយើងនឹងបានទៅកាន់ព្រះគោជាយានរបស់ព្រះឥសូរ ដូចពួកឥណ្ឌូនោះកាលណា ក៏នឹងទៅអាល័យព្រះគោនោះឬ កាន់ថាគោសព្វនេះ ជានាមព្រះគោតម ព្រោះព្រះពុទ្ធជាម្ចាស់យើងជាវង្សគោតមគោត្រត្រូវគ្នានឹងគោសត្វបានជារាប់អានគោរពគោ ទើបតាំងសិតសាងជារូបគោ តាំងជាទីបូជារបស់ខ្មែរដែលកាន់ព្រះពុទ្ធសាសនាអើបើដូច្នោះ សត្វគោក្នុងស្រុកខ្មែរនេះក៏មានទូទៅហេតុម្តេចខ្មែរក៏នៅនាំគ្នាប្រើគោជាពាហនៈ ជាយានបរទេះភ្ជួរស្រែ ហើយព្រមទាំងសម្លាប់ស៊ីសាច់ផងហេតុម្តេចក៏មិននាំគ្នាសំពះបូជាគោសព្វថ្ងៃនេះទៅផង



គោជាគោដូចគ្នា ៗ

ន័យមួយវិញទៀត មានពួកខ្លះជឿសំពះរូបយាយទេព បន់ស្រន់យាយទេព ដោយក្តីប្រាថ្នា អ្នកកាន់សំពះយាយទេពនេះ ក៏ពុំដឹងដើមហេតុរឿងប្រវត្តិនៃយាយទេពនោះជាអ្វី រូបយាយទេពនោះកាលរស់នៅ តើគាត់ជាទេវតា ឬ ជាមនុស្សយើងនេះគាត់ជាប្រពន្ធតាណា តានោះឈ្មោះអ្វី កាលរស់នៅ តើមានបុណ្យបារមីអាចជួយដោះទុក្ខខ្មែរយ៉ាងណាខ្លះឬ បានជួយប្រាប់សត្រូវខ្មែរយ៉ាងណាខ្លះ ជួយការពារសព្វទោសយ៉ាងណាខ្លះ មានគុណនឹងផែនដីយើងនេះដូចម្តេចខ្លះ, តម្រារឿងប្រវត្តិយាយទេពនោះ តើមាននៅក្នុងតម្រាពង្សាវតារឬក្នុងគម្ពីរសាស្ត្រាបាលីឯណាបានជាពួកនេះទៅជឿទៅបូជាអួតថាពូកែនោះ ៗ អើបើដូចជារូបនាងសាន្តារ៍ មានក្នុងពង្សាវតារបារាំងសែស នោះទើបគួរដល់លោកអញ្ជូនកជាតិបារាំងសែសគេគោរពបូជា ព្រោះនាងកាលរស់នៅនោះ បានជួយអាសាមហាក្សត្រ ចេញជានាយទាហានលើកពលយោធាច្បាំងនឹងពួកបច្ចាមិត្រ វាយយកខេត្តដែនរបស់ជាតិខ្លួនបានមកវិញ ដល់ក្រោយនាងអស់បុណ្យដោយដៃពួកបច្ចាមិត្រចាប់ទៅដុតភ្លើងទាំងរស់ពួកអ្នកនគរ..

គេនឹកដល់គុណនាង ដែលជួយយកអាសាផែនដីនោះ ទើបគេនាំគ្នាសិតសាងរូបនាងទុក គឺជាស្រីអស្ចារ្យតម្កល់ឲ្យពួកជាតិដូចគ្នាគោរពបូជារបស់គេ ត្រាលុះដល់មកសម័យឥឡូវនេះ ។

ឯយាយទែពនោះ តើកាលគាត់រស់នៅ បានជួយដោះទុក្ខជាតិខ្មែរយើងយ៉ាងណា ទើបបានបុរាណចាស់គេសាងរូបយាយទែពនេះទុក ឲ្យពួកខ្មែរយើងគោរពបូជារូបគាត់ ត្រាដល់មកឥឡូវនេះ ។

មួយទៀត ពាក្យទែពសព្ទនេះ ជាភាសាក្លាយមកពីភាសាសំស្ក្រឹតថា "ទៃត្យ" ប្រែថាខ្មោចយក្ស, អើរឿងខ្មោចយក្សនោះ សឹងជាសត្រូវនឹងជាតិមនុស្សយើងនេះទេ ហេតុម្ដេចក៏គេទៅបូជាវានោះទៀត ឬពាក្យទែពសព្ទនោះ ពុំមែនជាទែពនោះទេ គឺថាសព្ទទេពហៅថានាងទេពធីតា សំដៅយករូបនាងឧមាភគវតី ជាអគ្គមហេសីនៃព្រះឥសូរនោះទេដឹង? ព្រោះមនុស្សជាន់ដើមកាន់សាសនាព្រះឥស្សរាធិបតី រាប់អាននាងឧមាភគវតី ព្រោះនាងជាមហេសីនៃព្រះឥសូរនោះទើបគេសិតសាងរូបនាងតាំងទុកមក ហៅថា យាយទេពៗ នោះដល់យូរមកយារពាក្យហៅថាយាយទែព យ៉ាងនេះទេដឹង? អើបើទុកជារូប



នាងឧមាភគវតីក្ដី យើងជាឧបាសកឧបាសិការាប់អានព្រះពុទ្ធសាសនានេះមិនត្រូវទៅគោរពសំពះបូជារូបយាយទេពនោះទេ ធ្វើឲ្យសៅហ្មងខាតបង់ត្រៃសរណគមន៍របស់ខ្លួនសោះទទេយ៉ាងនេះ ។

មួយទៀត មានអ្នកខ្លះទៅជឿពាក្យព្រេង និយាយកុហកកូនក្មេងតមកថា ភ្នំក្រោមនៅខេត្តស្រុកសៀមរាប១ ភ្នំត្រងិលនៅខេត្តស្រុកជើងព្រៃ១ ភ្នំទាំង២នេះ ពុំមានដើមឈើដុះលើច្រូងច្រាងដូចយ៉ាងភ្នំឯទៀត ។ គឺភ្នំនេះកាលព្រះរាមចងថ្នល់លើកពលពួកពានរ ទៅយុទ្ធនានឹងក្រុងរាពណាសូរនៅកោះលង្កា បានប្រើឲ្យកំហែងហនុមានជញ្ជូនថ្មភ្នំចងថ្នល់ ។ ហនុមានមានរិទ្ធិខ្លាំងចងភ្នំតូចធំនិងសរសៃរោមហើយហោះមកឯភ្នំពីរនេះដាច់ចាករោមហនុមានធ្លាក់សំយុងចុះក្រោមបាតឡើងលើ ទើបឈើមិនដុះបាន កូនក្មេងឥតសតិបញ្ញាជឿតាម ប្រកាន់មាំថាមែន ដល់ខ្លួនចាស់ក៏នៅតែជឿ ព្រោះពុំមានសតិសម្បជញ្ញៈនឹងពិចារណាមើលហេតុមើលបច្ច័យ ធម្មតាលោកឡើយ ដូចនិទានរឿងតាហូឡាន មានកូនប្រសា ២នាក់ ។ ចៅបងជាមនុស្សឥតសតិបញ្ញាឮតែពាក្យអាពុកក្មេកថាដូចម្ដេច ក៏ធ្វើតាម ឯតាហូឡាន ក៏..

ស្រឡាញ់រាប់អានចៅបងនោះ ៗ ឯចៅប្អូនពុំគាប់ចិត្តអាពុកក្មេកព្រោះជាអ្នកមានសតិបញ្ញា មិនផ្សំមិនប្របតាមការខុសការមិនគួរជឿ ៗ

ថ្ងៃមួយតាហូឡាន នាំចៅកូនប្រសាទាំង២ចុះទូកចែវទៅព្រៃដើម្បីទៅកាប់ឈើ លុះចែវទៅដល់ទីវាល១ ឮសម្លេងក្រៀលវាយំកងឡើង អាពុកក្មេកក៏សួរទៅកូនប្រសាថា អើជី សត្វក្រៀលសត្វត្រយងនោះ ម្តេចក៏វាយំសម្លេងឮខ្លាំងម្ល៉េះ? ៗ

កូនស្រាបងឆ្លើយថា បាទ! បានជាវាមានសម្លេងនោះ ព្រោះកវាវែង ទើបបានជាមានសម្លេងឮ ឯចៅកូនប្រសាប្អូនចែវកន្សែងបានឮពាក្យអ្នកទាំង២ និយាយត្រូវគ្នាដូច្នោះ ក៏ទាស់ចិត្តណាស់ ទើបឆ្លើយឡើងថា សត្វហ៊ីងកូនក្អាត់នោះ តើកវាវែងកាលណា ម្តេចវាមានសម្លេងឮដែរ ៗ

ឯចៅអាពុកក្មេកនិងកូនប្រសាបង ក៏ទាល់បញ្ញាពុំអាចឆ្លើយតប ទើបនាំគ្នាស្ងៀមនៅ លុះចែវទៅដល់ទីគោកទួល១ ទួលនោះរលីងពុំមានស្មៅដុះទើបអាពុកក្មេកសួរទៀតថា អើទីទួលនេះម្តេចពុំមានស្មៅដុះ? ឯចៅកូនប្រសាបងឆ្លើយថា កាលដើមតាព្រហ្មគាត់មកដាំបាយ ហើយគាត់ជាត់ទឹកបាយទៅលើទួលនេះ



ហេតុនេះទើបស្មៅដុះពុំបាន ព្រោះទឹកក្តៅត្រូវស្មៅស្លាប់អស់ ៗ

ចៅអាពុកក្មេកក៏ទទួលថា អើមែនទឹកបាយតាព្រហ្មគាត់ជាត់ដាក់ទៅលើទីនេះ ស្មៅឯងដុះឯណាបាន ៗ

ឯចៅកូនប្រសាប្អូនក៏ឆ្លើយកាត់ឡើងថា មនុស្សក្បាលតំពែកសក់វាមិនដុះនោះ តើតាព្រហ្មគាត់ជាត់ទឹកបាយដាក់លើដែរឬម្តេច? អ្នកទាំង២ ក៏ទាល់ស្ងៀមនៅ ៗ លុះចែវទៅដល់ទីជ្រុងភ្នំបានឃើញថ្មបែកប្រេះ អាពុកក្មេកក៏សួរថា អើហេតុអ្វីថ្មនេះក៏បែកដូច្នេះ ចៅកូនប្រសាបងឆ្លើយថា កាលព្រះរាមព្រះលក្ស្មណ៍លោកអូសព្រះខ័នមកត្រង់នេះ ថ្មនេះត្រូវនឹងចុងព្រះខ័ន ទើបវាបែកយ៉ាងនេះ ៗ ឯពុកក្មេកក៏តបថា អើព្រះខ័នព្រះរាមមុតណាស់ តែលោកអូសទៅត្រូវអ្វីៗ ហើយគង់បែកគង់ដាច់មិនខាន ៗ

ចៅកូនប្រសាប្អូនក៏ឆ្លើយកាត់ឡើងថា ចង្កេកក្លិតមនុស្សឃើងនោះ តើព្រះរាមអូសព្រះខ័នដែរឬ? បានជាវាបែកយ៉ាងនេះ?

ឯអ្នកទាំង២ ក៏ទាល់បញ្ញា មិនអាចហើបហាថាអ្វីតទៅទៀតឡើយ ទើបចែវទៅដល់ព្រៃឈើនាំគ្នាកាប់បានក៏វិលមកផ្ទះវិញ ៗ

ឯងស្ដាប់មើលចុះ មនុស្សយើងនេះ សឹងឥតសតិបញ្ញានឹងពិចារណាឲ្យឃើញធម្មតាលោកិយ ទៅជឿតែសំដីព្រេងនិយាយបញ្ឆោតកូនក្មេងលេងតៗ មកដូចតាហូទ្សាន ចាញ់សំដីចៅកូនប្រសាប្អូនដូចពណ៌នាមកនេះ ។

មួយទៀត ជាតិមនុស្សប្រុសយើង ទោះជាខ្លៅល្ងង់ឆោតយ៉ាងណាៗ ក៏ពុំទទួលខ្លួនថាឆោត ថាពុំចេះនោះឡើយ សឹងអួតថាខ្លួនចេះដឹង ថាខ្លួនមិនឆោតទាំងអស់ ។

ដូចនិទានចៅឆោតម្នាក់ជិះក្របីទៅស្រែ យកស្រូវ១ល្អីទៅសាបផង ចៅនោះគិតថា អញជិះក្របីនេះវាធ្ងន់វាហើយ បើឯងដាក់ស្រូវ១ល្អីនេះលើខ្នងវាទៀត វារឹតតែធ្ងន់គ្នាណាស់ គួរតែជួយទូលវាកុំឲ្យគ្នាធ្ងន់ពេក ចៅនោះគិតដូច្នោះហើយ ទើបជិះក្របីទូលស្រូវបរទៅកាន់ស្រែនៃអាត្មា ។

កាលណោះ មានមហាក្សត្រាធិបតី ប្រើរាជអមាត្យ ឲ្យដើររកមើលមនុស្សឆោត ក្នុងព្រះនគរក្រៅព្រះនគរ ថាបើមានមនុស្សឆោតនៅក្នុងទីណានោះ ឲ្យអមាត្យនាំមនុស្សនោះចូលទៅគាល់ នឹងព្រះរាជទានរង្វាន់ឲ្យរាជអមាត្យតាមក្ដីគាប់ ។ ឯអមាត្យក៏ដើរត្រាច់មើលមនុស្សទាំងឡាយ តាមតំបន់ពុំមាន



ឃើញមានមនុស្សឆោត១ឡើយ, លុះដើរមកដល់វាលស្រែបែរទៅឃើញចៅជិះក្របី ទូលល្អីស្រូវដូច្នោះ ក៏សំគាល់ថាចៅនោះឆោតពិតប្រាកដទើបសួរទៅថា ចៅឯងនេះ ជិះលើខ្នងក្របីហើយស្រូវ១ល្អីនោះ ម្ដេចមិនដាក់លើខ្នងក្របីទៅម្ដេចចាំទូលផង ចៅឯងម្ដេចឆោតម៉្លេះ ចៅឯងឆោតឬឆ្កួតយ៉ាងណា? ឯចៅនោះ ពុំទទួលខ្លួនជាឆោតល្ងង់ទើបតបទៅថាខ្ញុំបាទនឹងឆោតល្ងង់កាលណា គឺខ្ញុំបាទចេះ ចេះគិតឃើញថាខ្លួនជិះលើខ្នងគ្នាៗធ្ងន់មួយសាហើយ សមដាក់ស្រូវ១ ល្អីថែមលើខ្នងគ្នាទៀតក្ដីធ្ងន់គ្នាក៏រឹតទ្វេឡើង ។ ហេតុនោះខ្ញុំបាទមេត្តាក្របីខ្ញុំបាទ ទើបជួយទូលវាយ៉ាងនេះ ហេតុដូចម្ដេចក៏លោកមកពោលថា ខ្ញុំបាទឆោតល្ងង់នោះ ។

ឯរាជអមាត្យនិយាយពន្យល់ទៀត ចៅនេះ ក៏មិនទទួលតាម ថាខ្លួនឆោតឡើយ រាជអមាត្យអស់ប្រាជ្ញា ទើបគិតថា មែនហើយមនុស្សយើងនេះប្រតិបត្តិការខុស ឆោតល្ងង់ ជាប់នូវក្ដីប្រកាន់ខ្ជាប់ហើយ ទោះគេនិយាយពន្យល់យ៉ាងណាៗ ក៏តាម នៅរឹងទទឹងដោយទិដ្ឋិខ្លាំងៗ រាជអមាត្យដើររកមនុស្សឆោតល្ងង់ទទួលខ្លួនជាឆោតល្ងង់ពុំបានឡើយ ហើយក៏ចូលទៅព្រះនគរ

ក្រាបទូលស្តេចដោយសេចក្តីរកពុំបានមនុស្សទទួលខ្លួនឆោតល្ងង់ដូចពណ៌នាមកនេះ។

មានរឿងតម្រាឃ្លានស្រឡាញ់ចុះឆោត ដូចសត្វសិង្ហតោ១ បានឃើញកូនក្រមុំចៅនាយដំឡៅម្នាក់ក៏កើតចិត្តស្រឡាញ់ចង់បានជាភរិយា ទើបចូលទៅនិយាយនឹងដំឡៅ ជាមាតាបិតានៃនាងថា ខ្ញុំស្រឡាញ់កូនក្រមុំលោក សូមលោកមេត្តាដល់ខ្ញុំឯរឿងតែងអាវាហមង្គលនោះ សូមឲ្យលោកបង្គាប់មកចុះ ខ្ញុំនឹងរៀបមកជូនឲ្យពេញចិត្ត កុំឲ្យលោកកោតញញើតឡើយ។

ឯដំឡៅនោះ ឮសិង្ហតោ មកពោលពាក្យចង់បានកូនខ្លួនជាប្រពន្ធដូច្នោះ ក៏គិតថា អាសិង្ហតោនេះជាជាតិថយថោក មិនគួរនឹងលើកកូនក្រមុំឲ្យជាភរិយាឲ្យខូចវង្សកូនអញ បើនឹងមិនឲ្យវាៗ ជាសត្វអង់អាចកាចឃោរឃៅ វាអាងចង្កូមនិងក្រចកជើងវាជាអាវុធវានឹងយាយីឯង ឲ្យដល់នូវក្តីវិនាសទៅផ្សេងៗ បើដូច្នេះ មានតែនិយាយលល្បួង កាត់អាវុធវាចេញទើបកែខ្លួនសុខបាន គិតហើយ នាយដំឡៅនិយាយទៅថា អើសិង្ហតោ អ្នកឯងមកចង់បានកូនយើងជាភរិយានេះ យើងក៏គាប់ចិត្តណាស់ ចង់បានបាឯងជាកូនជាចៅពិតៗ ព្រោះយើងឥតឫទ្ធិអំណាចនឹង



រកស្រាវជ្រាវត្រកូលឲ្យមាំមួនតទៅ តែខាងចិត្តកូនស្រីយើងនេះជាវាស្ម័គ្រព្រាក់ព្រមស្រឡាញ់បាឯង ឬយ៉ាងម្តេចនោះ យើងពុំបានទាន់ដឹង បើដូច្នោះ ចូរបាឯងនៅនេះសិនចុះ ចាំយើងចូលទៅនិយាយនឹងវាមើលសិន ថាហើយទើបចូលទៅក្នុងផ្ទះបន្តិច ក៏ចេញមកវិញ ហើយនិយាយថា យើងបាននិយាយនឹងកូនយើងស្រេចហើយ វាព្រមស្ម័គ្រនឹងអ្នកឯងដែរ តែវាថា អ្នកឯងមានក្រចកវែងស្រួចណាស់ ក្រែងបានគ្នាទៅ អ្នកឯងលូកប្រឡែងលេង បិចថ្ពាល់ បិចដោះក្តី វាខ្លាចក្រែងមុតថ្ពាល់ មុតដោះ, មួយទៀត ក្រែងអ្នកឯងថើបឱបជញ្ជួបថ្ពាល់ឬ មុខមាត់ទៅ ប៉ះត្រូវចង្កូមនឹងមុត ហេតុនេះ បើអ្នកឯងឲ្យយើងកាត់ចង្កូម កាត់ក្រចកចេញខ្លះនោះ ទើបកូនយើងវាព្រម។

ឯសិង្ហតោ លុះអំណាចក្តីឃ្លានស្រឡាញ់គ្របសង្កត់ ក៏ឆោតទើបថា អញ្ជើញលោករកគេមកកាត់ក្រចកកាត់ចង្កូមខ្ញុំចុះ ថាហើយ ក៏ដេកហាមាត់លាត់ក្រចកឲ្យនាយដំឡៅកាត់, នាយដំឡៅក៏ហៅកូនក្មួយជួយគ្នាកាត់គ្រឿងអាវុធនៃសិង្ហតោនោះ។ ឯសិង្ហតោនោះ ក៏លុះត្រូវគេកាត់ក្រចកដកចង្កូមអស់ហើយក៏សៀ្បយកម្លាំង សៀ្បយឫទ្ធិចុះ, ឯនាយដំឡៅនោះដឹងថា សិង្ហតោអស់ឫទ្ធិ

ហើយ ក៏ហៅពួកកូនក្មួយជួយគ្នាដេញវាយសិង្ហតោ, អ្នកខ្លះបានដំបង ខ្លះបានដាវលំពែង តាំងដេញចាក់ ដេញប្រហារសិង្ហតោៗអស់ឫទ្ធិនឹងតស៊ូ ក៏រត់ចូលព្រៃទៅ បានស្តេចក្តីវេទនាផ្សេងៗហោង ។

រឿងនេះ ឯងស្តាប់មើលចុះ ហើយប្រៀបដោយមនុស្សយើងសព្វថ្ងៃនេះ មានលោកចៅអធិការ ឬលោកអ្នកឯណាៗ មានសម្បត្តិ ត្រូវមេស្រីអ្នកលេងវាបញ្ឆោតដោយកលតាមទាគ ថាវាដោយហើយ លើកសម្បត្តិឲ្យទៅវាមុនអស់ ដល់ខ្លួនសឹកទៅ វាគេចជាមិនស្នេហាវិញ នឹងទារយកទ្រព្យសម្បត្តិវិញ វាគេចកែប្រែជាពុំបានទទួល មិនបានដឹងឮទ្រព្យនោះ នឹងយកវិញពុំបាន ដូចយ៉ាងសត្វសិង្ហតោ ឲ្យគេកាត់ក្រចកដកចង្កូមអស់ គួរគិតមើលទៅទៀតចុះ តាមរឿងឃ្លានស្រឡាញ់ឆោតនេះឯង ។

និទានក្នុងទសជាតកថា កាលមហោសថបណ្ឌិត រត់ចោលនាងអមរាទេវី ភៀសអាត្មាជាមនុស្សសាមញ្ញ ទៅនៅអាស្រ័យនឹងពួកស្មូនឆ្នាំងនោះក្រោយនោះ អាចារ្យទាំង៤នាក់ គឺអាចរ្យសេនក១ អាចារ្យបុក្កុល១ អាចារ្យកាមិន្ទ១ អាចារ្យទេវិន្ទ១ អាចរ្យ



ទាំង៤ នោះដឹងថា ព្រះមហោសថបណ្ឌិតរត់ចេញចាកលំនៅ ដោយកលឧបាយរបស់ខ្លួនដែលទូលញុះញង់ ឲ្យព្រះបាទវិទេហរាជកើតស្អប់ចៅមហោសថនោះ សមក្តីប្រាថ្នាខ្លួនហើយ ក៏មានចិត្តត្រេកអរក្រៃពេក កើតចិត្តប្រមាថនាងអមរាទេវីជាភរិយានៃពោធិសត្វ ចង់បាននាងជាភរិយាទីទៃៗ, តែកាលអាចារ្យទាំង៤ គិតទៅចង់នាងអមរានោះសឹងគិតគំនិតរៀងខ្លួន នឹងបានដឹងគ្នាក៏ទេ ។

ថ្ងៃមួយ, អាចារ្យទាំង៤ ប្រើមេអណ្តើកឲ្យនាំយកមាស់ប្រាក់ទៅជូននាង ហើយនិយាយផ្លូវលោកិយផ្សារស្រីមេម៉ាយប្តីបង់ចោល ។

ឯនាងអមរា កាលនាបើដឹងថា អាចារ្យទាំង៤ ចង់បាននាងដូច្នោះហើយក៏និយាយប្រាប់មេអណ្តើកទាំង៤ នាក់នោះថា ខ្លួននាងជាស្រីមេម៉ាយប្តីរត់ចោល នៅកណ្តែងឯកាឥតទីពឹង ឥឡូវបើលោកអាចារ្យមេត្តាប្រោសនាង ឲ្យបានទីពឹងនោះនាងក៏សែនត្រេអរ នឹងគុណលោកអាចារ្យណាស់ហើយនាងក៏ព្រមតាមអធ្យាស្រ័យ តែឯងទៅប្រាប់នាយឯងទីទៃៗថា បើលោកចង់មកផ្ទះនាងនោះ ឲ្យអញ្ជើញមកវេលាយប់ស្អែកនេះ ថាហើយ

ទើបសរសេរជាសំបុត្រកំណត់សញ្ញាពេលឲ្យមក ស្រេចហើយ
ប្រគល់ឲ្យមកមេអណ្ដើកទាំង៤ ឲ្យនាំទៅឲ្យនាយនៃខ្លួនទីទៃៗ
ក្រោយនោះ នាងអមរាចាត់ប្រើទាសាទាសី ឲ្យជីករណ្ដៅ១
ជម្រៅលិចក្បាលហើយឲ្យយកលាមកចាក់ទឹកឲ្យរលាយចំនួនត្រឹ
មចង្កាមាត់ ហើយឲ្យធ្វើជាយន្តគន្លឹះ បិទបាំងតាំងនូវពាងទឹក ហើ
យទាសាទាសីចាំនៅរក្សា នាងឲ្យសញ្ញាដល់ទាសីទាំងឡាយ
តាមឧបាយនាងគិតនោះឯង ៗ

ឯអាចារ្យសេនក លុះបានទទួលសំបុត្រនាងបានអានមើលដឹង
សេចក្ដីហើយ ក៏ត្រេកអរក្រៃពេកលុះដល់រាត្រីម៉ោង៨ អាចារ្យ
ក៏រៀបចាត់ចែងតែងកាយ ស្លៀកពាក់សមគួរហើយ ក៏ចេញចា
កគ្រឹះស្ថាន ដើរឆ្ពោះទៅកាន់ផ្ទះនាងអមរា ដល់ហើយក៏ឈរនៅ
មាត់ទ្វារ គោះទ្វារជាសញ្ញា ៗ

ឯពួកទាសីទាសានាងអមរា បានឃើញអាចារ្យសេនកមកដល់
ក៏នាំគ្នាចេញទៅទទួល ហើយនាំចូលទៅក្នុងបន្ទប់ទឹក និយាយ
ប្រលោម ថា "លោកនាយ, ខ្ញុំម្ចាស់ផ្ដាំថា បើលោកតាមកដល់សូម
ឲ្យលោកតាងូតទឹកជម្រះសរីរកាយ បំព្រំប្រោះទឹកអប់សិន សូម
អញ្ជើញឡើងតំណាក់ព្រះនាង" ៗ



ឯអាចារ្យសេនក ត្រូវមេទាសីវាប្រលោម ក៏ព្រមផ្លាស់សំព
ត់ដោះអាវ ចិញ្ចៀនពេជ្រឲ្យមេទាសីវាកាន់ឲ្យ មេខ្លះនាំចូល
ទៅក្នុងថ្លែងបន្ទប់ ឲ្យអង្គុយលើក្ដារយន្ត មេខ្លះយកផ្ដិលប្រាក់
ដងទឹកស្រោច មេខ្លះធ្វើជាជួយដុសក្អែលឲ្យ លុះងូតបន្តិចមេ
អស់នោះទាញយន្តឡើង ឯក្ដារនោះក៏ភ្លាត់បាកទីបះឡើង.
អាចារ្យសេនក ក៏ធ្លាក់ចុះទៅក្នុងរណ្ដៅអាចម៍នោះ ដើបតែក
ឡើងឲ្យផុតអំពីលាមកនៅរងទុក្ខដូចសត្វនៅគូថនរក
នោះឯង ៗ

ថ្លែងឯអាចារ្យបុក្កុសនោះ លុះដល់យប់ម៉ោង៩ ក៏បាត់ចែង
តែងខ្លួនទៅផ្ទះនាងអមរា, ឯពួកមេទាសីវាក៏ប្រលោម ដូចបទ
អាចារ្យសេនកហើយ វាទាញយន្តទម្លាក់អាចារ្យបុក្កុសនោះ
ទៅក្នុងរណ្ដៅគូថជាមួយនឹងអាចារ្យសេនកនោះឯង ៗ

លុះដល់ពេលម៉ោង១០ អាចារ្យទេវិន្ទទៅចុះកលដូចអាចារ្យ
ទាំងអស់, អាចារ្យទាំង៤ នៅក្នុងរណ្ដៅគូថរងទុក្ខវេទនាដោយ
លាមកដោរពោរឡើងដល់ត្រឹមចង្កាមាត់ បានដឹងគ្នាថាចុះកល
នាងអមរាទេវីនៅរងទុក្ខអស់១រាត្រី លុះព្រឹកឡើងនាងអមរា
ប្រើពួកទាសីទាសា យករងកទាក់កអាចារ្យទាំង៤ ទាញឡើង

ចាកវណ្ណៅ ហើយឲ្យយកទឹកចាក់លាងសព្វសារពាង្គកាយនៃអាចារ្យ ឲ្យយកដុំឥដ្ឋដុសក្បាលអាចារ្យទាំង៤ ។

ឯអាចារ្យទាំង៤ បានសេចក្ដីឈឺចាប់ដោយមេទាសីវ៉ានួសកោសដុសដោយដុំឥដ្ឋនោះឯង លុះជម្រះលាងកាយអាចារ្យភ្ជាប់គ្នា ហើយឲ្យអ្នកបម្រើសែងអាចារ្យដូចគេសែងខ្មោច, នាងក៏ចូលទៅក្នុងព្រះរាជវាំងនាំយកអាចារ្យទាំងនោះ ទៅថ្វាយដល់ព្រះបាទវិទេហរាជ, ស្ដេចឲ្យស្រាយសំណុំកន្ទេលមើល ស្រាប់តែឃើញអាចារ្យទាំង៤ នៅក្នុងនោះទើបទ្រង់ត្រាស់សួរនាងអមរាៗក៏ក្រាបទូលតាមដំណើរអាចារ្យទៅកំហែងប្រមាថនាង តាំងអំពីដើមដល់ចប់សព្វប្រការ ។

ព្រះបរមរាជាបានទ្រង់ស្ដាប់ដូច្នោះក៏ទ្រង់ព្រះពិរោធខ្ញាល់និងអាចារ្យទាំង៤ហើយទ្រង់ត្មះតិះដៀលដោយពាក្យអាក្រក់ផ្សេងៗ ទ្រង់បណ្ដេញឲ្យទៅផ្ទះរៀងខ្លួនទីទៃ ។

ឯអាចារ្យទាំង៤បានសេចក្ដីអប្បយសខ្មាសអស់បណ្ដាមហាជនទាំងឡាយពុំអាចនឹងទៅកាន់ទីជំនុំប្រជុំជនានុជនផងបាន ខានចូលព្រះរាជវាំងអំពីថ្ងៃនោះមក ។

ឯនាងអមរាទេវីលុះសម្រេចកិច្ចខ្លួនហើយក៏ក្រាបថ្វាយបង្គំលា



ស្ដេចនាំពួកបរិវារនាងវិលទៅកាន់គ្រឹះស្ថាននាងវិញហោង ។

រឿងនិទាននេះមានសេចក្ដីពិស្ដារក្នុងគម្ពីរទសជាតកឯណោះ មានសេចក្ដីតទៅទៀតយើងទាញយកតែបទត្រង់នេះមកសម្ដែង ដើម្បីឃើញសេចក្ដីត្រង់តម្រាឆោត កើតដោយសេចក្ដីឃ្លានស្រឡាញ់នេះឯង ។

**ចប់តម្រាឃ្លានស្រឡាញ់ឆោត**

អាចារ្យបាំងឈើ ភ្លើៗទៅលើ នួននាងអមរា ជាកល្យាណី ស្ត្រីមានបញ្ញា បំពោតឲ្យអា ចារ្យធ្លាក់វណ្ណៅ ទោសគឺក្ដីស្នេហ៍ ឆោលុះទាល់តែ បង់ប្រាណបាននូវ ក្ដីធ្លាក់ថ្លស់យស ខុសនឹងព្រះចៅ តម្រានេះហៅ ឆោតឆៅព្រោះស្ត្រី ។

## តម្រាឃ្លានអាហារឆោត

មានសត្វក្រពើ១នៅក្នុងបឹងធំលុះដល់រដូវប្រាំងទឹកបឹងនោះក៏រីងខះអស់ក្រពើនោះនៅពុំបានទើបវ៉ាឡើងគោកដើរត្រាច់រកទីមានទឹកនឹងអាស្រ័យ ។

ឯក្រពើក៏សូមដោយសាររទេះតានោះ តានោះសួរថា "ចៅឯងតើនឹងទៅឯណា? ក្រពើប្រាប់ថា "ខ្ញុំបាទនេះរកទីអាស្រ័យពុំបានគឺបឹងដែលខ្ញុំបាទធ្លាប់នៅនោះ ឥឡូវទឹករីងខះអស់និង

នៅតទៅពុំបាននឹងទៅស្វែងរកបឹងឬស្ទឹងទន្លេឯណា ដែលមានទឹកនោះនឹងអាស្រ័យនៅ ថាបើតាមេត្តានាំខ្ញុំបាទទៅបានដល់ទីត្រង់ណាដែលមានទឹកនោះ សូមតាមេត្តាដាក់ខ្ញុំបាទត្រង់ទីនោះចុះ"។

ឯតានោះក៏ព្រម ទើបដោះគោចេញចាកនឹមហើយឲ្យក្រពើឡើងជិះលើទូករទេះ ឯក្រពើនោះខ្លួនវែងក៏លូនក្រាបក្បាលដល់ក្បាលក្រពើរទេះហើយមិនទុកចិត្តខ្លួនក្រែងធ្លាក់ ទើបឲ្យតានោះយកខ្សែមកចងខ្លួនភ្ជាប់នឹងទូករទេះ តានោះក៏ធ្វើតាមពាក្យក្រពើស្រេចហើយ តាក៏ទឹមគោបរចេញអំពីទីព្រៃនោះលុះត្រាដល់ទីបឹងមានទឹក១, តានោះក៏បញ្ឈប់រទេះដោះគោចេញ ហើយស្រាយចំណងក្រពើប្រាប់ថា "បឹងនេះគួរហើយចូរអ្នកឯងលូនទៅនៅបឹងនេះចុះ"។

ឯក្រពើជាសត្វអកតញ្ញូមិនដឹងគុណគេមានសេចក្ដីឃ្លានអាហារដោយអត់មកយូរថ្ងៃហើយក៏និយាយទៅថា "តាឯងនេះចងយើងភ្ជាប់ទូករទេះយើងបានសេចក្ដីទុក្ខវេទនាពន់ពេកណាស់តាឯងត្រូវឲ្យគោយើង១ស៊ីទើបតាឯងរួចទោសថាបើមិនឲ្យគោដល់យើងទេ ត្រូវយើងស៊ីតាឯងក្នុងកាលឥឡូវនេះ"។



ឯតានោះលុះឮក្រពើពោលពាក្យដូច្នោះ ក៏ភិតភ័យទើបស្ដីអង្វរថាអ្នកក្រពើខ្ញុំឯងនេះមានគុណបានដឹកនាំបាងឯងមកដល់ទីនេះ ឥឡូវបានឹងស៊ីខ្ញុំវិញការនេះ ខ្ញុំឯងឥតទោសសោះមិនគួរនឹងពិឃាតបើដូច្នេះ ខ្ញុំពុំសុខចិត្តចាំខ្ញុំទៅរកលោកចៅក្រមឲ្យលោកវិនិច្ឆ័យរឿងក្ដីនេះសិន សឹមប្រតិបត្តិទៅមក, ឯក្រពើក៏ព្រមថា "អើ តាឯងទៅរកចៅក្រមណាក៏ទៅឲ្យឆាប់ចុះយើងពុំខ្លាចទេ"។

ឯតានោះបានចេកទុំ១ស្និត ក៏កាន់ដើរទៅរកចៅក្រម, កាលនោះមានសន្សាយគល់១ នៅលើទួលដំបូកបានឃើញតាកាន់ចេកដើរកាត់ព្រៃចូលមក ទន្សាយក៏សួរទៅថា "តាអើយតាៗឯងមាននេត្រាផលដោរសោកសៅ ដោយមានទោសទុក្ខយ៉ាងណា? មកនេះតើនឹងទៅស្ថានឯណា?។

ឯតានោះក៏និយាយសេចក្ដីខ្លួននិងក្រពើកើតហេតុនឹងគ្នាប្រាប់ទន្សាយនោះសព្វប្រការ។

ទន្សាយបានស្ដាប់ដូច្នោះក៏ថាអើអាសត្វក្រពើនោះ ជាសត្វមិនដឹងគុណតាឯង បើដូច្នោះខ្ញុំនឹងទទួលទៅជាចៅក្រមជម្រះឲ្យតាឯងកុំភ័យឡើយឲ្យតែចេកនោះមកខ្ញុំស៊ីសិន សឹមទៅជាមួយ

គ្នា ។ តានោះក៏ឲ្យចេក១ ស្និតទៅសុភាទន្សាយៗបរិភោគចេក នោះអស់ហើយ ក៏នាំគ្នាទៅទីតំណាក់ដែលឈប់នោះ ដល់ហើយ សុភាទន្សាយនិយាយទៅថា "ម្ដេចចៅក្រពើចៅឯងវង្វេងផ្លូវ ទំព្រមមិនដឹងជាទៅណាបានតាគាត់មេត្តាឲ្យដោយសារមកផង ឥឡូវបានដល់ទីសមគួរ និងរកអាស្រ័យនៅហើយម្ដេចចៅគិត ទេវរឃ្នើគុណគេ គិតនឹងស៊ីគេវិញគេធ្វើទុក្ខទោសអ្វីឲ្យដល់ ចៅឯង" ។

ឯក្រពើក៏ឆ្លើយថា "អើលោកសុភាតានេះគាត់ឲ្យខ្ញុំដោយសារមកនេះក៏មែនប៉ុន្តែគាត់ធ្វើបាបខ្ញុំខ្លាំងណាស់គឺគាត់ចង់ខ្ញុំភ្ជាប់ ទៅនឹងទូករទេះខ្លាំងពេក រកតែនឹងរេខ្លួនដកដង្ហើមក៏ពុំបាន គាត់ធ្វើទុក្ខខ្ញុំយ៉ាងនេះបានជាខ្ញុំខឹង ត្រូវឲ្យគាត់ប្រគល់គោគាត់ បាន១ ឲ្យខ្ញុំស៊ី ថាបើគាត់ពុំព្រមឲ្យគោនោះទេត្រូវស៊ីគាត់ វិញ" ។

ទន្សាយក៏ឆ្លើយអនុលោមតាមថា "អើតាៗឯងចងគេតឹងខ្លាំង ហួសបានជាគេខឹង ចុះតាឯងម្ដេចក៏ចងគ្នាតឹងម្លេះ គ្នារកតែរើខ្លួនមិនរួចដូច្នោះតា?" ។

តានោះថា "ទេ, ខ្ញុំបាទចងធូរទេលោកចងល្មមតែជាប់ពុំឲ្យ



ធ្លាក់ប៉ុណ្ណោះឯង" ។

ទន្សាយថា "អើខាងចោទថាចងតឹងខ្លាំងខាងចម្លើយថាចង ធូរ, ពាក្យទាំង២នេះសឹងពុំមានបន្ទាល់សាក្សីអាងអើបើដូច្នោះ ចៅក្រពើឯងលូនឡើងលើទូករទេះវិញ ឲ្យតាគាត់ចងម្ដងទៀតយើងនឹងមើលឲ្យដឹងជាតឹង ឬធូរជាសាក្សីនឹងបានកាត់សេចក្ដី នេះឲ្យជាយុត្តិធម៌ទៅបាន" ។

ឯក្រពើជាសត្វខ្លៅ ក៏វារឡើងទៅក្រាបលើទូករទេះឲ្យ តានោះចងដូចមុន តានោះយកបំណងតាំងចងដូចមុនវិញ ទន្សាយសួរថា "ម្ដេចចៅកុម្ភា, តាគាត់ចងតឹងយ៉ាងនេះឬ? ក្រពើក៏ ឆ្លើយថា "ទេលោកកាលគាត់ចង់ខ្ញុំមុននោះ តឹងលើសនេះខ្លាំង ណាស់បើចង់តែប៉ុណ្ណោះខ្ញុំនឹងទៅខឹងអ្វីនឹងគាត់" ។ ទន្សាយថា "អើ ចូរតារឹតខ្សែទ្វេឡើងទៀតឲ្យគេសុខចិត្ត" ។ តានោះក៏ រឹតចំណងឡើងទៀត ។ ទស្សាយសួរថា "ម្ដេចចៅកុម្ភាម្ដងនេះ តើជាតឹងដូចកាលជាន់មុននោះហើយឬ? ក្រពើថា "នៅពុំទាន់ ស្មើចងមុននោះទេ" ។ ទន្សាយថា "តាឯងកាប់ឈើមកធ្វើជាកូន កំព្រារឹតម្ដងទៀតទៅ" តានោះក៏ធ្វើតាមហើយតាំងត្រែបង រឹតទាំងមុខទាំងក្រោយពេញកម្លាំង ឯក្រពើនោះត្រូវត្រែបង

កូនកំព្រាខ្លាំងតឹងខ្លួនស្ទើរតែដកដង្ហើមចេញពុំបានទើបឆ្លើយថា "សូមទានកាលជាន់មុននោះគាត់ចងតឹងយ៉ាងនេះឯង, លោកអើយនរណាទៀយនឹងអត់បានសូមលោកជាសាក្សីមើលចុះ ជាអ្នកឯណាខុសឯណាត្រូវ" ។

ទន្សាយឃើញក្រពើខ្លួនពុំរួចហើយទើបបង្គាប់តានោះថា "តាចាំអ្វីទៀតពូថៅធំក្នុងរទេះនោះមិនយកមកពុះក្បាលវាទៅ ទុកឲ្យរស់ធ្វើអ្វីខ្មោចអាសត្វអកតញ្ញូពុំដឹងគុណគេដែលធ្វើលើខ្លួន" តាចាស់នោះបានឱកាសដោយទន្សាយប្រាប់ដូច្នោះក៏ស្ទុះទៅយកពូថៅធំមកសំពងកាប់កាត់ក្រពើនោះជាកំណាត់តូចធំ ក្រពើក៏លុះនូវក្តីអន្តរាយជីវិតហោង ។

សុភាទន្សាយបង្គាប់ថា "កង់កន្ទុយវានោះតាឯងឆ្អើរដាក់យកទៅស្លពីសាឬចង់ញាំក៏ជា ឯពោះវៀនបត់ចន្ទាសវានោះញាំភ្លាជាណាស់តាអើយ" ។

ឯតានោះធ្វើតាមសុភាទន្សាយប្រាប់សព្វប្រការហើយយកចេកត្រសក់ជូនទន្សាយដោយក្តីខ្លួនផុតអន្តរាយនឹងក្រពើ ស្រេចហើយយកគោមកទឹមរទេះលាសុភាទន្សាយបរទៅកាន់ទីឋានខែនអាត្មាហោង ។



ក្រអើយក្រពើ គេមានគុណលើ មិនដឹងគុណគេ ចៅបានដល់បឹង
គិតខឹងវិបវេ ត្រឡប់ខាំគេ ឲ្យសូន្យជីវិត ។ ធ្លាក់កលឧបាយ
សុភាទន្សាយ ឲ្យចង់ចៅភ្និត នឹងទូករទេះ ស្រមេះអស់រិទ្ធិ
ចៅបង់ជីវិតដោយពូថៅតា ។

តម្រាឃ្លាន គិតបញ្ឆោត លុះគេបោទ ឆោតប្រាប់គេ

កាលណោះ ព្រះពុទ្ធជាម្ចាស់យើង នៅក្នុងកាលសាងបញ្ញាបារមីអន្ទោលជាតិ កើតជាសត្វពានរហៅថា មហាកបិន្ទ កបដោយកម្លាំងក្លាហានអាស្រ័យនៅព្រៃត្រើយស្ទឹងធំ១ ស្ទឹងនោះមានកោះ១ ឯក្រពើញីប្រពន្ធពោលដូច្នោះ ក៏លោមទៅថា "ទិ៍ហមេកុម្ភីមាសបង! នាងមានក្តីបំណងប៉ងសាច់ថ្លើមនៃពានរនោះ ជាភ្នាក់ងារបងនឹងទៅរកមកឲ្យប្អូនបានក្នុងកាលថ្ងៃនេះ ព្រោះមានផ្លូវ១ នៅខាងលើទឹយើងមានមហាពានរ១ តែងលោតផ្លោះឆ្លងពីត្រើយទៅកោះ ពីកោះទៅឯត្រើយវិញ ដូច្នេះបងនឹងទៅចាំលាក់ខ្លួនពួនអែបនៅខាងដុំថ្មធំ ចាំគោះមហាពានរនោះត្រាតែបាន", ថាហើយចៅកុម្ភីក៏ហែលលីលាត្រង់ទៅទីដុំថ្មធំ ដល់ហើយតាំងឡើងក្រាបលើទីថ្ម ធ្វើអាការដូចថ្មដើម្បីពោធិសត្វសំគាល់ថាជាដុំថ្ម និងលោតទៅលើខ្លួននឹងងាយចាប់ ។

ឯមហាកបិន្ទរាជ លុះពេលល្ងាចត្រជាក់បរិភោគកបដោយផ្លែឈើមើបឈើបរិបូណ៌ទីក្បាលកោះនោះមានដីខ្សាច់នឹងដុំថ្ម១ដុះនាកណ្ដាលទីនោះជិតនឹងត្រើយ ពោធិសត្វតែលោតផ្លោះអំពីត្រើយទៅដល់កោះនោះ ដើម្បីស្វែងផលាផលរាល់ៗថ្ងៃ ។

គ្រាកាលណោះមានសត្វក្រពើញីឈ្មោលជាប្ដីប្រពន្ធអាស្រ័យនៅក្រោមស្ទឹងនោះឯង លុះនៅយូរមកមេក្រពើនោះផើមគឺមានគភ៌នឹងពងកើតក្ដីទោហលាចំណង់ចង់ស៊ីថ្លើមពានរ ទើបនិយាយនឹងក្រពើឈ្មោលថា "ខ្ញុំមានក្ដីចង់ទទួលទានថ្លើមមហាពានរនោះជាខ្លាំងណាស់បើអ្នកមិនគិតរកឲ្យខ្ញុំបរិភោគក្នុងសម័យនេះខ្ញុំនឹងស្លាប់ចោលអ្នកឯងជាប្ដីសម្លាញ់ហើយ" ។

ផលាផលផ្អែតហើយនឹងវិលទៅខាងត្រើយនាយវិញលុះលោតចុះចាកកោះផ្លោះមកដល់ទីឆ្នេរស្ទឹងហើយនឹងលោតទៅជាន់ដុំថ្មកណ្ដាលនោះ បែរទៅឃើញកុម្ភាក្រាបលើថ្ម ក៏កើតក្ដីសង្ស័យគិតថាថ្មនេះសព្វកាលទៀងមក តែងទាបត្រឹមខ្នងទឹកនេះទេ ថ្ងៃនេះហេតុអ្វីក៏ថ្មនេះខ្ពស់ដូច្នេះទំនងជាមានសត្វកំណាចមកដេកក្រាបលើថ្មនេះ ដើម្បីយាយីជីវិតអាត្មាប្រាកដ ពោធិសត្វគិតដូច្នោះហើយ ក៏ពោលពាក្យហៅទៅថា "ថែហដុំថ្មដ៏...



ប្រសើរអើយ! អើខ្លួនចៅឯងនេះសព្វកាលទៀងមកពុំដែលលូតខ្ពស់ហួសអំពីខ្នងទឹកនេះទេថ្ងៃនេះ ហេតុអ្វីក៏ថ្មឯងលូតខ្ពស់លើសកាលមុនៗហះ? ពោធិសត្វពោលហៅថ្មយ៉ាងនេះ មិនតែម្ដងគឺហៅអស់វារៈ៣ដង ។

ឯក្រពើក្រាបលើថ្ម ឮពានរហៅថ្មជាគំរប់៣ ដងក៏គិតថាថ្មនេះកាលពីដើមទំនងជាចេះនិយាយ ទើបបានពានរនេះហៅប្រស្រ័យ ឥឡូវឯងមកដេកក្រាបលើខ្នងវា បានជាវានិយាយតទៅនឹងស្វាវិញពុំរួច បើដូច្នោះមានតែអញឯងក្លែងនិយាយជួសថ្មនេះទើបបានស្វានេះវាលោតមក ព្រោះថ្មនេះនឹងស្វានោះគេធ្លាប់ចរចាប្រស្រ័យនឹងគ្នា គិតហើយចៅកុម្ភាក៏ឆ្លើយតបទៅថា "ថែហមហាកបិន្ទរាជ អ្នកឯងសង្ស័យនឹងយើងថា លូតខ្ពស់ហួសអំពីមុននោះឬ? យើងតាំងនៅដដែល ដូចកាលមុននោះទេអញ្ជើញលោតមកជាន់យើងដូចកាលមុនៗនោះចុះ" ។

ឯបរពោធិសត្វ បានឮក្រពើពោលតបមកដូច្នោះក៏ថា "ភោនរណាមកពោលពាក្យតនឹងយើងនេះថ្មយើងធ្លាប់ជាន់នេះ មិនចេះនិយាយជាភាសាលោកទេ នេះគឺរូបនរណាពោលប្រាប់មកយើងនេះ" ។

ឯក្រពើនោះលុះឮដូច្នោះក៏ទាល់បញ្ញានឹងគេចខ្លួនពុំរួចទើប ឆ្លើយប្រាប់តាមក្ដីពិតថា "យើងនេះគឺតួមហាកុម្ភានៅនាទីស្ទឹងនេះណា៎ពានរ" ។

"ឱចៅមហាកុម្ភាទេហះ! អើហេតុអ្វីក៏ចៅមកដេកក្រាបលើថ្មនេះ?" ។ "នែចៅពានរយើងនេះមានសេចក្ដីប្រាថ្នាចង់បានសាច់ផ្លែមបេះដូងនែចៅឯងនឹងនាំទៅឲ្យភរិយាយើងបរិភោគ" ។

"ឱ! បើចៅប្រាថ្នាជីវិតយើងដូច្នោះចូរចៅហាមាត់ធ្មេចភ្នែកឡើង យើងនឹងលោតទៅត្រង់ឥឡូវនេះ ។ ឯក្រពើនោះក៏តាំងហាមាត់ឡើងបង្គ្រាងធំធ្មេចភ្នែកទាំង២ ជិតប្រុងចាំត្របាក់ពានរ ។ ឯពោធិសត្វមានឱកាសហើយក៏លោតផ្លោះស្ទុះទៅអំពីទីទាបត្រង់ទៅជាន់លើក្បាលចៅកុម្ភាហើយផ្លោះទៅដល់ត្រើយនាយដោយកម្លាំងខ្លាំងលឿន ដូចខ្យល់មួយរំពេច ពោធិសត្វក៏ទៅដល់ទីលំនៅនៃអាត្មា ។

ឯមហាកុម្ភាដឹងថាពានរលោតផុតខ្លួនៗចាប់ពុំទាន់ដូច្នោះ ក៏កើតក្ដីទោមនស្សតូចចិត្ត ដោយចាញ់កលមហាបិន្ទុរាជ គឺអាត្មាឆោតខ្លៅពិតៗ ហើយក៏ចុះពីខ្នងសិលាម្នីម្នា ហែលទៅកាន់ទីរូងក្បាលកោះជាទីលំនៅអាត្មាវិញហោង ។



រឿងនិទាននេះ មានសេចក្ដីពិស្ដារនៅក្នុងគម្ពីរចរិយាបិដកឯណោះមើលចុះ ។

(ចប់រឿងឆោតដោយក្ដីឃ្លានអាហារ)

# តម្រាឆោតដោយស្រវឹងយសឡើងបញ្ជោរ

(ពាក្យអានជាបទ) កាកគតិតែង តំណាល់តំណែង ដំណើរ
បក្សា ក្អែកគោកមួយនៅ លើចុងរុក្ខា សែនសុខស្ដា-ពរពិតឥត
មោះ ។ ថ្ងៃ១បក្សី ចេញស្វែងចំណី តាមភូមិកៀនកោះ ឃើញ
អ្នកនិគម ហាលនំទឹកដោះ ក្អែកអរហើយផ្លោះ ចុះចោះចឹកបាន
។ កាងស្លាបហើរស្លោ តម្រង់ត្រង់ទៅ បែរមើលទីឋាន ដាន
ដែលយាត្រា ។ កាលនោះមានសត្វ សំពោច១ធាត់ស្វែងរកភោ
ក្តា មកដល់យល់ក្អែក ទំមែករុក្ខាមាត់ពាំនំប្រា-កដជាចំណី ។

សំពោចគិតថា អញនឹងចរចា បញ្ជោរបក្សី ឲ្យវាហាមាត់
ភ្លាត់ធ្លាក់ចំណី ជ្រុះមកដល់ដី បានអញវិញណា ។ គិតហើយទើប
ពោល ជាពាក្យបញ្ជោរ ទៅកាន់ក្អែកថា ក្អែកអើយអ្នកក្អែក
រូបឯកសោភា ចំពុះដូចជា ខ័នកែវមរកដ ។ រោមស្លាបស្រស់
ស្រិល រលង់ដូចនិល រលើបម៉ត់ចត់ ចង្កុះសមទ្រង់ ជង្គង់សម
បទ វង់មុខសមមាត់ សមមានលក្ខណា ។

រូបអ្នកឧត្តម បើតាមក្បួនខ្ញុំ ទំនាយទាយថា នឹង បានសម្រេច
ជាស្ដេចបក្សា តែស័ព្ទសភា ពុំទាន់ប្រស្យ័ក្ត ៗ បើសិនអ្នកស្រែ
ខ្ញុំព្ទសម្រែក សូវសមចំសក្តិ ខ្ញុំហ៊ានទំនាយ ទាយថាអ្នកជាក់ បាន
ជាចមចក្រ កំពូលបក្សា ៗ

ក្អែកឡើងអួត ព្ទគេសង្កួត សរសើរអញ ចង់ឲ្យគេស្ដាប់
សូរស័ព្ទសភា ទើបឈរឡើងហា មាត់ស្រែកចេញខ្ញី ៗ ឯនំពាំ
នោះ ធ្លាក់ពីចំពុះ ជ្រុះមកដល់ដី សំពោចស្រុះស្រួល ទទួលចំណី
ហើយបែរស្រដី ចំអកបក្សា ៗ ក្អែកអើយចៅក្អែក អ្នកឯង
បែងចែក ចំណីនេះណា យើងពេញចិត្តគាប់ចិត្ត ដ្បិតអ្នកយល់
ថា យើងជាហោរា ទទួលខាន់ខៅ ៗ ជាហើយចៅក្អែក ប្រព្រឹត្ត
នេះឯក ឥតមានហ្មងសៅ អ្នកឯងទៅរក មកទៀតណាំចៅ ពី
ថ្ងៃនេះទៅ យើងបានពឹងផង ៗ ថាហើយសំពោច បែរប្រាណ
ស្ទុះផ្លូច ចូលព្រៃដូចប៉ង កាកោបង់នំ ក្រំចិត្តកន្លង ពុំដឹងទំនង
ខ្មោចលងភក្សា ៗ

និទានរឿងនេះ អញ្ជើញប្រាជ្ញបេះ ត្រិះមើលកិរិយា ក្អែក
ចង់ចំណី ព្រោះក្ដីប្រាថ្នា ក្នុងបសំសា បាយ៉សង្កួត ៗ

នរូអ្នកណា មានចិត្តប្រាថ្នា ចង់ឲ្យគេអួត នឹងដូចក្អែកខ្មៅ



ត្រូវគេសង្កួត ឆោតឡើងអំនួត បង់នំឯងអើយ ៗ

(ចប់តម្រាឆោតព្រោះសរសើរ)

# តម្រាឆោតព្រោះមានះ

(ពាក្យបទព្រហ្មគីត) តម្រាកម្រើកចិត្ត អាងឥទ្ធិរិទ្ធិ៍ ឥតវិញ្ញាណ
ថាគ្រានោះមែនមាន សត្វចចកមួយអប្រិយ ៗ នៅក្នុងគោហា
ស្ងាត់ អស្រ័យសត្វជាចំណី ដោយសារសត្វរាជសីហ៍ ជាមិត្រភ័ក្ត
ស្មោះស្មាគម ៗ ថ្ងៃ១ចចកចរ ឡើងសិង្ហរចូល យល់ថ្មដា១ធំ ភ្លឺ
ដូចឋានកញ្ចក់ឆ្លុះ ៗ ចចកយល់ថា នែអាត្មានៅក្នុងនោះ ដឹងជា
ស្រមោលប្ចោះ កើតក្ដួបចិត្តគិតទ្រុស្ដមិត្រ ៗ
គិតថាទៅមុសាប្រាប់សីហា ក្រកបឬទ្ធិ ថាមានបច្ចាមិត្ត
ចង់លងឫទ្ធិជំនាញជ័យ ៗ

មិត្រអញកាន់មានះ អាងតបះកំហែងហល់ តែថាបញ្ញាទាល់
យល់ស្រមោលគង់បោលជាក់ ៗ មែនបើមិត្រប្រហារ ត្រូវថ្មដា
នោះជៀងជាក់ គល់កមិត្រគង់បាក់ សូន្យជីវិតពិតពុំខាន ៗ

បើរាជសីហ៍ស្លាប់ សាច់ជាភព្វអញឯងបាន អាស្រ័យទទួល
ទាន ឃើញជាមានរសឱជា ៗ ចចកគិតប្ចោះហើយ ពុំលង់ឡើយ
ទើបយាត្រា ទៅប្រាប់រាជសីហា ដល់ហើយថាហៃមហាមិត្រ ៗ

ឥឡូវមានរាជសីហ៍ មួយនៅទីល្អាងវិចិត្រ អួតថាខ្លួនប្រសិទ្ធ ចង់លងឫទ្ធិនឹងមិត្រឯង ៗ

រាជសីហ៍ស្តាប់ចចក និយាយឡកដោយកលលេង ស្មានពិតដូចពាក្យថ្លែង កើតជឿចិត្តឥតសង្ស័យ ៗ ទើបតបថាអើចៅ មកយើងទៅជំនាញជ័យ ខ្លាចអ្វីអាសត្វព្រៃ នៅឯណាចចក ៗ

ចចកនាំរាជសីហ៍ ឡើងគិរីកាត់ឈូងចក ដំរាបទៅដល់ច្រក ល្អាងសិលាថ្មដាផ្ទុះ ៗ ចចកក្លែងធ្វើខ្លាច មកក្រោយរាជសីហ៍ស្ទោះ ខ្សឹបថាហ្ន៎អីនោះ មិត្តមើលចុះនោះវាហើយ ៗ វាគ្មានព្រឹមមិត្តទេ ឈរចំអែនៅកន្ទើយ បើមិត្តធ្វើម្តេចហើយ វាក៏ធ្វើតបវិញស្តែង ៗ រាជសីហ៍ជឿស្ទុះចូល យល់ស្រមោលអាត្មាឯង ស្មានសត្វដទៃផ្សេង ទើបសម្តែងឫទ្ធិសីហា ៗ ស្ទុះក្រាបចាក់ក្រាញក្រោយ កន្ទុយកោយកន្ទុះរាសំញេញញញាក់ភក្ត្រា ធ្វើកិរិយាចូលជាញជ័យ ៗ រូបភាពស្រមោលនោះ ខ្លួនធ្វើដូច្នោះវាច្នោះដែន រាជសីហ៍ទោសោព្រៃ ស្ទុះទះទល់ផល់ថ្មដា ៗ លុះត្រូវសិលាឡាក់ កក៏បាក់ដល់ពិការ រាជសីហ៍សូន្យសង្ខារ នៅនាកាលនោះឯងដែន ៗ

អនិច្ចាសត្វសីហា ភ្លើងទោសាដុតឲ្យក្ស័យ មោហោបញ្ញាខ័យ ជំនាញជ័យនឹងរូបឯង ៗ លុះនៅវិនាសប្រាណ នេះព្រោះ



គ្មានបញ្ញាឈ្វេង យកតែមានះឯង មកសម្តែងតាំងជាមុខ ៗ មានះនេះខូចខ្លួន ចុះក្នុងក្បួនលោកតាំងទុក មានះនាំបុករុក នាំមនោឲ្យម្ទេញអើយ ៗ

(ចប់តម្រាឆោតឆាងអាងមានះ តែត្រឹមនេះហោង)

# តម្រាឆោតព្រោះឃ្លានមាន

មានចៅព្រានព្រៃម្នាក់តែងដើរបរបាញ់សត្វម្រឹគបក្សីយកមកចិញ្ចឹមជីវិតនៅជាប្រក្រតី ថ្ងៃ១ចៅព្រានព្រៃទៅស្វែងបរបាញ់ក្នុងព្រៃលុះពេលល្ងាចក៏ត្រឡប់វិលមកផ្ទះ ដើរមកដល់ព្រៃ១មានដើមឈើធំ១ដើម ដុះនៅខាងផ្លូវមានមេសេក១ ទៅធ្វើសំបុកភ្ញាស់កូន នៅលើចុងឈើនោះឯង ៗ

ចៅព្រានព្រៃដើរមកជិតនោះហើយពោលពាក្យថា ថ្ងៃនេះពេលក៏ចួនល្ងាចណាស់អញនឹងឡើងយកកូនសេកនៅសំបុកនេះពុំទាន់ បើដូច្នោះ ចាំព្រឹកស្អែកចុះនឹងមកយកវាទៅស្លស៊ី ថាហើយចៅព្រានព្រៃក៏ដើរហួសទៅផ្ទះ ៗ

ឯមេសេកនៅលើសំបុក លុះបានឮពាក្យព្រានព្រៃគុំនឹងយាយីដូច្នោះ ក៏កើតក្តីភ័យសោកស្តាយបុត្រ នឹងជីវិតអាត្មាថា ឮឱអញអើយ! កើតមកជាសេកនេះ ជាសត្វឥតពិសឥតអាវុធ

នឹងតនឹងមនុស្សនោះសោះ ឥឡូវវាថាព្រឹកស្អែកនេះវានឹងមកយកកូនអញទៅអាស្រ័យ ឱ! បើកូនអញដល់នូវសេចក្ដីវិនាសហើយ តើជីវិតអញឯណាក៏នឹងតាំងនៅបានគង់អញស្លាប់តាមកូនអញមិនលែងឡើយ, ឱកូនអញអើយ! តូចៗពេកពុំទាន់ដុះក្រាសដុះស្លាបឲ្យមាំមួននឹងបាននាំបង្ហើរចេញឲ្យផុតអំពីសត្រូវនេះ, មួយទៀតអញនឹងគិតរកសត្វណា អាចនឹងជួយបានអេះ!ៗ

ឱ!បើគិតទៅឃើញឧបាយ១ ល្មមកែខ្លួនបានគឺអញមានសត្វពស់វែក១ នៅឯដំបូកខាងនោះ ពស់នោះជាសម្លាញ់នឹងអញមកយូរហើយ ចាំអញទៅនិយាយ ឲ្យសម្លាញ់ជួយដោះទុក្ខនេះទើបបាន កាលដែលសេកនោះ គិតដូច្នោះក៏ហើរទៅកាន់សំណាក់ពស់ ដល់ហើយក៏និយាយប្រាប់ពស់ តាមរឿងចៅព្រានព្រៃវានឹងមកចាប់កូនខ្លួន ក្នុងវេលាថ្ងៃព្រឹកនេះឯងៗ

ឯពស់វែកឮដូច្នោះក៏អាណិតសេកជាសម្លាញ់ទើបទទួលជួយដោះទុក្ខសេក ទើបផ្ដាំសេកថា បើព្រាននោះវាឡើងនឹងយកកូនសេកឯងកាលណា ឲ្យសេកឯងនិយាយអង្វរសូតវាថា លែងតែអ្នកមេត្តាកុំយកកូនខ្ញុំចុះ ខ្ញុំនឹងប្រាប់ទីកំណប់មានប្រាក់កែវកងនៅទីដំបូកនោះឲ្យអ្នក ក៏ឯជាតិមនុស្សនោះតែឮត្រង់កំណប់



មាសប្រាក់ហើយ គង់ចង់បានលើសកូនសេក ១·២ នោះជា ១០០ គុណគង់ឲ្យសម្លាញ់ឯងនាំផ្លូវវាមកដំបូកនេះ សម្លាញ់ឯងចូរប្រាប់វាថាទីត្រង់នេះហើយ វានឹងលូកដៃមកក្នុងរន្ធនេះមិនខាន បើវាលូកដៃមកកាលណាហើយ ខ្ញុំឯងនឹងចឹកវាឲ្យលុះដល់មរណកាលនាទីនេះឯង ឯសម្លាញ់ឯងក៏នឹងរួចអំពីអន្តរាយ ៗ

·មេសេកនោះបានស្ដាប់ឧបាយពស់ប្រាប់ដូច្នោះហើយ ក៏ត្រេកអរដ៏ក្រៃពេក ទើបលាពស់ហើរវិលត្រឡប់មកទ្រនំវិញ ចូលក្រាបគ្របគ្រងកូននៅអស់មួយរាត្រីកាល លុះអរុណរឿងរះស្រឡះមេឃាចៅព្រានព្រៃក៏ម្នីម្នារៀបអាត្មា ទៅកាន់ដើមឈើធំ ដល់ហើយក៏លាត់សំពត់វ៉ែណ្ណគាតខ្ជាប់ឡើងដើមឈើ ដើម្បីយកកូនសេកៗ

ឯមេសេក ឃើញចៅព្រានឡើងជិតដល់ប្រគាបឈើកាលណាក៏ស្ទុះហើរមកទំមែក១ ហើយនិយាយទៅថា បពិត្រអ្នកជាមនុស្សអ្នកឯងខំព្យាយាមឡើងឈើនេះ ដើម្បីសាច់កូនសេកនិងសាច់ខ្ញុំជាមេនេះ សេចក្ដីប្រាថ្នាអ្នកនឹងសម្រេចហើយ តែសាច់កូនសេកនិងសាច់ខ្ញុំនេះ អ្នកបរិភោគទៅក៏បានឆ្អែតតែក្នុងថ្ងៃនេះឯង ដល់ថ្ងៃស្អែកខានស្អែក អ្នកនឹងឃ្លានវិញ ហេតុ

នោះចូរអ្នកកុំប្រាថ្នាសាច់សេចស៊ី១ ពេលនេះទៀយចូរអ្នកចុះទៅយកកំណប់ឯទីជើងដំបូកឯណោះវិញ មានប្រយោជន៍លើសថ៍លែងសាច់សេកនេះជា១០០គុណ ៗ បើអ្នកចង់បានខ្ញុំឯងហើរនាំអ្នកទៅកាន់ទីកំណប់នោះ ៗ

ឯចៅព្រានទ្រៃព្រាបានឮសេកប្រាប់ទីកំណប់ដូច្នោះក៏ត្រេអរទ្រៃក្រពេកណាស់ទើបថាអើសេកបើឯងប្រាប់ទីកំណប់ អញបានមាសប្រាក់ដូចឯងថានេះហើយ អញថ៍លែងយកកូនសេកឯង មកយើងទៅឥឡូវនេះ ថាហើយក៏ចុះចាកឈើលុះដល់ដី មេសេកបក្សីក៏ហើរនាំផ្លូវទៅត្រង់ដំបូកអាសិរពិសពស់វ៉ែកដល់ហើយក៏ស្រែកប្រាប់អំពីលើថា អ្នកព្រានទ្រៃព្រនោះហើយទីរណ្ដៅកំណប់មាសប្រាក់ តាមចិត្តអ្នកប្រាថ្នាកាយយកចុះ ៗ

ឯចៅព្រានចង់មានខ្លាំងក៏តាំងលូកដៃចុះទៅក្នុងរន្ធពស់ដោយឥតពិចារណាឯពស់វ៉ែកនោះ ក៏ចឹកដៃព្រានទ្រៃព្រមួយទំពេចពិសពស់នោះក៏ផ្សព្វផ្សាយកាយ ចៅព្រានទ្រៃព្រ ដល់ក្ដីមរណកាលនៅជើងដំបូកនោះឯង ៗ

ឯមេសេកឃើញចៅព្រានទ្រៃព្រដល់ក្ដីមរណៈ ក៏អស់ក្ដីសត្រូវខ្លួនពីថ្ងៃនេះឯង ហើយក៏ហើរនាំទៅទ្រនំ ទំគ្រប់គ្រងព្យាបាល



កូនដំរាបចម្រើនធំនាំទៅរកស៊ីតាមនិស្ស័យហោង ៗ

ចប់ គម្រាគោតឃ្លានមានអន្តរធានប្រាណ។

ចប់ភាគ៣ តែប៉ុណ្ណោះ។